# សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
# KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 1 (267) 253-3947


មាតិការឿង

Vol 07 Issue 135- August 12th- 22th. 2013 Free


១-សប្តាហ៍បង្ហាញពីភោជនីយដ្ឋាន..........០៣
២-ភ្ញៀវជាតិ និងអន្តរជាតិប្រមាណ១ម៉ឺននាក់..........០៥
៣-ការបញ្ចេញមតិដោយសេរីរបស់ពលរដ្ឋ..........០៨
៥-ហេតុអ្វីក៏ស្ពានទូតនៅភ្នំពេញក្រឡាបងប្អូន.......០៩
៦-The Cambodia daily..........១២&១៣
៧-ក៏ព្យសំណាត់ដែលប្រជាជនរដ្ឋខ្មែរត្រូវតែ..........១១
៨-វត្តព្រះពុទ្ធរង្សីធ្វើពិធីប្រណាំងទូកនាគ..........១៤
៩-ជនជាតិខ្មែរជិបុងបំផុតដែលរស់នៅក្រុង..........១៥



New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852


## វិចារណកថា

## វិរៈបុរសខ្មែរនៅបរទេស

**ខ្មែរប៉ុស្ដិ៍ ស.រ.អា**

ខ្មែរនៅបរទេស១០នាក់បានស្ម័គ្រចិត្តចូលបំរើជាតិតាមរយៈគណបក្សសង្គ្រោះជាតិ ហើយឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌលផ្សេងៗអ្នកទាំង១០នោះបានទទួលជោគជ័យយ៉ាងត្រចេះត្រចង់ដោយបានជាប់ឈ្មោះក្លាយជាតំណាងរាស្ត្ររួចហើយ ។ អ្នកទាំងនោះមាននាម : ១-វេជ្ជបណ្ឌិត កែវ សម្បត្តិ (Lowell-USA) ២- នុត រំដួល (Lowell-USA)៣-អ៊ុំ សំអាន (Lowell-USA)

តទៅទំព័រទី ២១

## ដំណឹងចុងក្រោយ : ទស្សនៈកិច្ច
## សម រង្ស៊ី_ស៊ូមូរ៉ា នៅឡូវែល

**ដោយ : ពិន សំខុន**

ប្រជាពលរដ្ឋនៅឡូវែលប្រមាណ៨០០នាក់ មកពីច្រើនតំបន់នៃស.រ.អា. បានមកទទួលប្រធានគណបក្សសង្គ្រោះជាតិគឺលោក សម រង្ស៊ី ដែលទើបនឹងបញ្ចប់ តទៅទំព័រទី ៤

# ឡូវែលត្រៀមធ្វើពិធីប្រណាំងអុំទូកឆ្នាំ២០១៣





វេន ពេជ្រ :ប្រធានគណកម្មការបុណ្យអុំទូក

**ខ្មែរប៉ុស្ដិ៍ ស.រ.អា**

ថ្ងៃទី១៧ សីហា ពីម៉ោង៩ ដល់ ៥ល្ងាច ប្រជាពលរដ្ឋរាប់ម៉ឺននាក់នឹងមកជួបជុំគ្នានៅក្រុងឡូវែលនាមាត់ទន្លេ "មេរីម៉ាក" ដែលហូរទន្ទឹមមហាវិថី"ផទូខេត" ដើម្បីមើលការប្រណាំងទូករៀបចំដោយ Lowell Southerst Asian Water festival នៅពេលដដែលនោះ នៅបណ្ដោយដងទន្លេមុនទំនប់ទឹកធ្លាក់ តទៅទំព័រទី ៧

# ខ្មែរបេញបោះឆ្នោតព្រមគ្នាគណបក្សណាជាអ្នកដឹកនាំ?

**ដោយៈ ពិន សំខុន**

ពលរដ្ឋខ្មែរបញ្ចេញមតិច្បាស់លាស់ព្រមគ្នា នាឱកាសបោះឆ្នោតសាកលថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០១៣ បានផ្ដល់អំណាចថ្មីឱ្យគណបក្សសង្គ្រោះជាតិបានធ្វើឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ទន់ឥរិយាបថយ៉ាងចំឡែក កាលពីថ្ងៃអង្គារទី៣០ គាំទ្រឱ្យបង្កើតគណកម្មាការចម្រុះសម្រាប់ស៊ើបអង្កេតនោះដែរ ។ គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនជាគណបក្សតែ២គត់ ដែលមានឈ្មោះក្នុងការប្រកាសលទ្ធផលរបស់គ.ជ.ប ។ ក្នុងចំណោមគណបក្សទាំង៨ដែលបានប្រកួតប្រជែងយកឈ្នះលើទឹកចិត្តប្រជារាស្ត្រខ្មែរលទ្ធផលចេញពីគ.ជ.ប គឺជាលទ្ធផលរបស់គណបក្សប្រជាជនដែលមានឥទ្ធិពលលើអង្គការបោះឆ្នោតជាតិថា គណបក្សប្រជាជនឈ្នះបាន៦៨អាសនៈ តទៅទំព័រទី ១៩








សមត្ថភាពរាប់សន្លឹកឆ្នោត


## ការិយាល័យ មេធាវី
## ថំមាស ស្តាលីយ៉ាណូស
**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

Immigration • Divorce • Auto Crash

▸ អន្តោប្រវេសន៍ ▸ គ្រោះថ្នាក់រថយន្ត ▸ លែងលះប្ដីប្រពន្ធ

Call: Sophea or Thomas សូមទូរស័ព្ទមក: សោភា ឬធំ
**978-459-5000 or 800-308-3766**
Only Licensed in Massachusets


ប្រើធនាគារឲ្យប្រសើរ
គឺនៅក្នុងកាបូប
FREE
$150 gift card to Coach®
កាតរង្វាន់$150ទិញកាបូបល្បីឈ្មោះ"ខូច"
ជាមួយការបើកសេវាសម្រាប់ប្រើធនាគាររាល់ថ្ងៃ
Washington SAVINGS BANK
washingtonsavings.com
* Restrictions apply Ask for details.
Customer will receive a free gift within 30 days after redeeming a "FREE GIFT Certificate" and implementing the following combination of new services after 12/10/2012: A monthly direct deposit of at least $1,000 from an unaffiliated third party, at least one monthly automatic withdrawal that is not web or card based and an active debit card with 12 or more completed purchases is eligible for a $150 Coach® gift certificate. Promotion ends 06/30/2013. Coach® is a trademark of Coach, Inc. The program is not endorsed by Coach, Inc. nor is there any actual or implied joint venture, partnership or relationship of any kind between Washington Savings Bank and Coach, Inc. Promotions cannot be combined, one gift per customer, per account, per household. Available to personal accounts only. Fee of $150 applies for account closure or change of services within 6 months of free gift receipt. Washington Savings Bank reserves the right to disqualify any account/ person from this promotion if, in its sole discretion, it determines the account and/or services are solely designed to qualify for the free gift. Limited time offer, while supplies last.

# សប្តាហ៍បង្ហាញពីភោជនីយដ្ឋានក្នុងតំបន់

**ដោយ : ខ្មែរផុស ស.រ.អា**

"កូឡាបក្រហម"ជាភោជនីយដ្ឋានខ្មែរតែមួយគត់ដែលស្ថិតនៅក្រុងខ្មែរដែលចូលរួមក្នុងកម្មវិធីបង្ហាញម្ហូបចំណីខ្មែររៀបរៀងដោយ Great Merrimuck Vally ប្រចាំឆ្នាំ២០១៣ ជាមួយនឹងភោជនីយដ្ឋានធំតូចជាច្រើនទៀត ។




ពីថ្ងៃអាទិត្យទី១៨ សីហា ដល់ទី១ កញ្ញា ២០១៣ សាធារណជនអាចអញ្ជើញពិសារអាហារថ្ងៃត្រង់ ឬល្ងាចនៅភោជនីយដ្ឋានដែលមានរាយនាមឈ្មោះខាងក្រោមដែលជ្រើសរើសមុខម្ហូប : ១-អាហារពិសេសថ្ងៃត្រង់មុខម្ហូប២មុខ ក្នុងម្លៃពី៩.១៣ ដល់១៥.១៣ដុល្លារ

២-អាហារពិសេសពេលល្ងាចមុខម្ហូប៣មុខក្នុងតម្លៃ២៣.១៣ដុល្លារ( តម្លៃនេះពុំបានបញ្ចូលពាក់ភេសជ្ជៈ និងធីបទេ) ។

នេះគឺជាកម្មវិធីឆ្នាំទី៤របស់ GMV ដែលចូលរួមដោយ Convention នឹង Visitor Burean រួមទាំង Chamber of Commerce នៅ Lowell នឹង Lexingtong ផង សម្រាប់បង្ហាញជូននូវម្ហូបចំណីប្រណិត ឈ្ងុយឆ្ងាញ់ពិសេសប្រចាំភូមិភាគដែល "កូឡាបក្រហម" ទើបបានចូលរួមជាលើកទី១ ។



Greater Merrimack Valley Restaurant Showcase Week

The Greater Merrimack Valley Restaurant Showcase Week

presented by

**Greater Merrimack Valley Convention and Visitors Bureau**
in partnership with the Greater Lowell Chamber of Commerce and the Lexington Chamber of Commerce.

Plan Your **Visit** Plan Your **Meeting** Plan Your **Group Tour** Plan Your **Sports Event**

## Restaurant Showcase Week 2013

Mark your calendars. From August 18th - September 1st, restaurants throughout the Greater Merrimack Valley region will participate in the Greater Merrimack Valley Fourth Annual Restaurant Showcase Week presented by the Greater Merrimack Valley Convention and Visitors Bureau in partnership with the Greater Lowell Chamber of Commerce and the Lexington Chamber of Commerce . Food lovers and diners will have the chance to sample some of the best cuisine in the Greater Merrimack Valley. You can dine on a two-course lunch or three-course dinner with fixed prices starting at just $9.13 for lunch and $23.13 for dinner.

**Sunday, August 18th through Sunday, September 1st**

All participating restaurants will offer a unique menu selection.

- Special 2-Course Lunch Menu: Prices range from $9.13 to $15.13
- Special 3-Course Dinner Menu: Prices range from $23.13 to $33.13

*Prices do not include taxes, beverages or gratuity.*

**Participating Restaurants**

Check back often for updated list of participating restaurants

**Angelina's Italian Restaurant and Pizzeria** Menus and More Info

**Athenian Corner Restaurant**

**Bahama Breeze**

**Centro Restaurant**

**Clark's at the Westford Regency** Menus and More Info

**Cobblestones**

**Glenview Restaurant and Pub** Menu and More Info

**Grazie at Four Oaks Country Club** Menus and More Info

**Heritage Farm Ice Cream and Restaurant** Menus and More Info

**LaBoniche** Menus and More Info

**Lexx Restaurant**

**Major's Pub**

**Merchant's Row at Concord Colonial Inn** Menus and More Info

**Minuteman Grille at the Holiday inn Boxborough** Menus and More Info

**Moonstones** Menus and More Info

**On The Bone at the Wyndham Boston Andover** Menus and More Info

**Owen & Ollie's Restaurant and Pub**

Pho Dalat Restaurant

**Red Rose Cambodia Restaurant**

Ricardo's Cafe' Trattoria

TreMonte Pizzeria

Vine Brook Tavern

50 Warren at UMass Lowell Inn and Conference Center

MIDDLESEX Community College
BEDFORD • LOWELL

**Classes begin Sept. 4**

**Register Now**

Fall 2013 programs include:

- **Paralegal Studies**
- **Culinary Arts**
- **Energy Utility Technology**
- **Hospitality Management**
- **Dental Laboratory Technology**

A great place to begin your future

More than 75 degree and certificate programs

Day, evening, accelerated and weekend courses, on campus and online

15 programs can now be completed entirely online!

- Two convenient locations in Bedford and Lowell
- Small class sizes and free tutoring services
- Disability support services
- Financial aid for those who qualify
- Academic, career & transfer counseling



To learn more or to register, call **1-800-818-3434** or visit **www.middlesex.mass.edu/fall**

**KhmerPost USA, LLC**
**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

ផ្សាយពាណិជ្ជកម្ម **Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office) |
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ **Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers: Loeum Im, Sokha Lim
**អ្នកនិពន្ធកិត្តិយស Contributed Writers:**
Kim Phien, Kim Sos, Mao Chan Somnom, Mam Yin,
Richard Howe Jr. Sengly Kong, Ph.D.
**ច្នៃសោភ័ណភាពកាសែត Design Artist**
Heng Chhunleng
**ជំនួយការរដ្ឋបាល Administrative Assistant**
Sokha Lim

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at $60.00 or 70 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

## តមកពីទំព័រទី ១ ទស្សនៈកិច្ច សម រង្ស៊ី នៅឡូវែល...

ការបោះឆ្នោតសាកលនៅកម្ពុជា កាលពីថ្ងៃទី២៨ កក្កដា កន្លងទៅនៅព្រឹកថ្ងៃសៅរ៍ ទី១០ សីហា



នេះ នាភោជនីយដ្ឋាន "សំពៅមាស" នៃទីក្រុងឡូវែល ។ លោក សម រង្ស៊ី បាននាំពាំសេចក្តីរាយការស្តីពីការសម្រេចចិត្តរបស់ពលរដ្ឋខ្មែរមកបោះឆ្នោតគាំទ្រគណបក្សសង្គ្រោះជាតិ និងការរំភើបចិត្តរបស់លោកដែលមិនដែលបានឃើញចលនាមហាជនដ៏ធំធេងមិនដែលមានពីមុនមក ។

ទទួលលោក សម រង្ស៊ី ថ្ងៃនេះជាព្រឹត្តការណ៍សំខាន់មួយដែលពលរដ្ឋរង់ចាំលទ្ធផលនៃការបោះឆ្នោតរង់ចាំដំណោះស្រាយបញ្ហាដែលបានធ្វើឱ្យការប្រកាសលទ្ធផលរាំងស្ទះរង់ចាំថានឹងមានបាតុកម្មតវ៉ាដោយសារការលួចបន្លំនាពេលបោះឆ្នោត ។ លោក សម រង្ស៊ី បានឆ្លៀតឱកាសមកពិធីមង្គលការកូនស្រីនៅឡូវែលដែលបានគ្រោងទុកច្រើនខែមកហើយនោះ **តទៅទំព័រទី ២៥**

LOWELL SOUTHEAST ASIAN WATER FESTIVAL
PRESERVATION & SHARING OF CULTURAL HERITAGE OF SOUTHEAST ASIAN COMMUNITIES




Greater Merrimack Valley Convention & Visitors Bureau
adventuresawait
MASSACHUSETTS IT'S ALL HERE!
massvacation.com
*For even more fun things to do and see, and great places to eat, visit our website at MerrimackValley.org. Come play and stay!*

LOWELL HERITAGE STATE PARK
ESPLANADE & SAMPAS PAVILION
500 PAWTUCKET BLVD.
LOWELL, MA 01854



# ភ្ញៀវជាតិ និងអន្តរជាតិប្រមាណ១ម៉ឺននាក់ ចូលរួមក្នុងពិធីបុណ្យប្រជាជន ឬ ហ្វូកហ្វែសធីវ៉លឆ្នាំ២០១៣

**ដោយៈសុខា**

**ក្រុងឡូវែលៈ** រយៈពេលបីថ្ងៃនៃចុងសប្តាហ៍នៅចុងខែកក្កដាឆ្នាំ២០១៣ កន្លងទៅថ្មីៗនេះ ចំកណ្តាលក្រុងឡូវែលមានភ្ញៀវជាតិ និងអន្តរជាតិចូលរួមយ៉ាងច្រើនកុះករ ដើម្បីមកកំសាន្តសប្បាយទទួលទានម្ហូបអាហារទិញអីវ៉ាន់សំបូរបែបនានាជិះរថភ្លើងកំសាន្តនៅសួនប្រវត្តិសាស្ត្ររាំលេងសប្បាយ ស្តាប់តន្ត្រីមើលការតាំងពិពរណ៌ចម្លាក់រូបស្ទូន ចម្លាក់ផ្ដែឈើវត្ថុអនុស្សាវរីយ៍ពីប្រទេសផ្សេងៗតួយ៉ាងកន្សែងសូត្រ ក្រមា បន្ទោងសោរធ្វើដោយដៃច្នៃជារូបសត្វផ្សេងៗនាំមកពីព្រះរាជាណាចក្រកម្ពុជា ។ល។ សារព័ត៌មានខ្មែរផុសបានចុះយកពត៌មានដោយផ្ទាល់ និងសាកសួរទៅកាន់អ្នកចូលរួមមានជាអាទិ៍ លោក យ៉ារីលីវ៉ាន់ ស្ថាបនិក ឡឥតផ្សេងនៅក្រុងឡូវែលដែលបានតាំងនូវវត្ថុឆ្លាក់រូបសូន ព្រមទាំងស្នាដៃគួរ










ឱ្យចាប់អារម្មណ៍ជាច្រើនទៀត។ លោកយ៉ារីលីវ៉ាន់ បានមានប្រសាសន៍ថា លោកអញ្ជើញចូលរួមបង្ហាញស្នាដៃក្នុងពិធីបុណ្យប្រជាជនច្រើនលើកមកហើយ ហើយនេះជាលើកទី៦។ លោកថ្លែងថា ពិធីបុណ្យនេះមានអត្ថប្រយោជន៍ក្នុងការផ្តល់ឱកាសដល់សហគន៍ឱ្យបានបង្ហាញនូវសម្លេង និងបញ្ចេញនូវស្នាដៃរបស់ពួកគេដល់សាធារណជនជាតិ និងអន្តរជាតិ ហើយពិធីនេះក៏ជាពិធីកំសាន្តលំហែកាយដោះដូរបទពិសោធន៍វប្បធម៌គ្នាទៅវិញទៅមកដែរ។ ចំណែកឯអ្នកស្រីហ្គ្លូរៀ អាឌីកជី Gloria Adigwe ដែលជានាយកសមាគមន៍ជនជាតិណាយជីរៀប្រចាំ ម៉ារីម៉ាកវ៉ាលី បានមានប្រសាសន៍ថា វាជាឱកាសបង្ហាញនូវវប្បធម៌អាហារហូបចុករបស់ជនជាតិណាយជីរៀ ហើយពួកយើងសប្បាយរីករាយនឹងចូលរួមកម្មវិធីនេះខ្លាំងណាស់។ ចំណែកខាងសិប្បកម្មមួយរបស់ខ្មែរដែលអញ្ជើញមកពីមាតុប្រទេសនៃព្រះរាជាណាចក្រកម្ពុជាមកពីខ្មែរអាធីហ្សានីបាននាំយកនូវផលិតផលខ្មែរដែលធ្វើដោយដៃដាក់តាំងបង្ហាញ និងលក់ជូនភ្ញៀវជាតិ និងអន្តរជាតិឱ្យបានជ្រាបពីគុណភាព និងស្នាដៃនៃផលិតផលខ្មែររួមមានសូត្រ ក្រម៉ា និងវត្ថុអនុស្សាវរីយ៍ជាច្រើនទៀត។ ក្នុងពិធីបុណ្យប្រជាជននេះផ្ទាល់មានការសហការ និងយកចិត្តទុកដាក់ពីស្ថាប័នក្នុងសហគមន៍ជាច្រើន ព្រមទាំងមានអ្នកស្ម័គ្រសម្រួលចរាចរវើសសម្រាមសម្អាតក្រុង ។ល។ ដែលញុំាងឱ្យពិធីបុណ្យនេះប្រព្រឹត្តទៅដោយភាតរភាព និងបរិយាកាសរីករាយ ៕





Gloria Adigwe

# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូសល្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិជលស់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie


## 287 Appleton Street, Suit 205 Lowell, MA 01852

## Tel: 978-459-5000

**E-mail: Tom@stylianoslaw.com**


Attorneys' only licensed in Massachusetts

## តមកពីទំព័រទី ១ ឡូវែលត្រៀមធ្វើពិធីប្រណាំងទូក...

"ផទូខេត"នឹងមានតូបតាំងផលិតផលសហគមន៍ចំនួន៧០ដែលបណ្ដាសហគ្រាស ឬពាណិជ្ជករ រៀបចំបង្ហាញភ្ញៀវនូវទំនិញរបស់ខ្លួន ឬម្ហូបអាហារ ជាពិសេសរបស់ជនជាតិអាស៊ីអាគ្នេយ៍ ឬផលិតកម្មនានាដែលកម្ររកបាន ។

ឱកាសបុណ្យអុំទូកនៅឡូវែលនោះ ជាពិធីរបស់ជនជាតិអាស៊ី អគ្នេយ៍ មានខ្មែរ ឡាវ វៀតណាម និងថៃ ដែលជាពិធីដ៏ធំធេងជាងគេបង្អស់នាឆ្នេរខាងកើតមានភ្ញៀវចូលរួមពី៥-៦ម៉ឺននាក់ក្នុងរយៈពេល១ថ្ងៃនោះ ៕



ក្រុមទាសំណាង
Lucky Ducky Team



ក្រុមគ្រួសារសាមគ្គី
Family Unity Team

| ក្រុមប្រណាំងទូក<br>**TEAM** | មេក្រុម<br>**CAPTAIN** |
|---|---|
| Angkorian Warriors (CASA)<br>ក្រុមទ័ពអង្គរ | Rob Sin<br>រ៉ុប ស៊ីប |
| Family Unity Boat Team (H&R Block)<br>ក្រុមគ្រួសារសាមគ្គី | Bunsong Suo<br>ប៊ុនសុង ស៊ូ |
| Living Root - Chips<br>ក្រុមគ្រាប់ពូជអមតៈ-ដំឡូង | Bryan Nelson<br>ប្រ៊ីយ៉ាន ណែលសិន |
| Living Root - Fish<br>ក្រុមគ្រាប់ពូជអមតៈ-មច្ឆា | David Parker<br>ដេវីដ ផាកឃឺ |
| Lucky Ducky (EMC Canoe Adventure Club)<br>ក្រុមទាសំណាង | Dennis Sheehan /<br>Douang Phommasinh<br>ដេនីស ស៊ីហាន់ |
| Payanak<br>បាយ៉ាណាក់ | |

### Water Festival Entertainment Schedule: 17 August 2013
**កាលវិភាគកម្មវិធីបុណ្យអុំទូកឆ្នាំទី១៧ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣**
**រក្សាសិទ្ធបើមានការផ្លាស់ប្តូរកាលវិភាគ**

**ផ្ដើមកម្មវិធីដោយ ដានី និង នីតា**
9:10 - Welcome speech by Dahnie and Nita
**សូត្រមន្តឲ្យពរ ដោយព្រះសង្ឃ**
9:15 - Blessing by Buddhist Monks
**សេចក្ដីផ្ដើមនៃការប្រណាំងទូក**
9:30 - Introduction of Boat races by Douang
9:45 - DJ will play music/audience dance participation
10:00 - Ghla's Band performs
10:30 - Thai Dance (1st performance)
10:40 - DJ will play music/audience dance participation
10:50 - Thai Dance (2nd performance)
**ប្រកាសប្រណាំងទូក**
11:00 - Announcements/Boat race updates
11:15 - Laos Dance (1st performance)
11:25 - Singer Johnny Dep aka JDep - (1st performance)11:35 - Laos Dance (2nd performance)
11:45 - Laos Band
**ប្រកាសប្រណាំងទូក**
12:10 - Announcements/Boat race updates
12:25 - Laos Dance (3rd performance)
12:35 - Khmer Band1:15 - Angkor Dance Troupe (1st performance)
**ប្រកាសប្រណាំងទូក**
1:25 - Announcements/Boat race updates
1:35 - "Fried Rice Eating Contest" begins!
1:55 - Angkor Dance Troupe (2nd performance)
2:05 - Adam's Dance Troupe 2:15 - Comedian Hella Chluy
2:30 - Johnny Dep aka JDep (2nd performance)
2:40 - Singer Melissa
2:45 - Stage Games with Dahnie and Nita
3:00 - Announcements for winner of Papaya Taste Testing Contest
**ប្រកាសប្រណាំងទូក**
3:15 - Announcements/Boat race updates
3:30 - Ghla's Band
**ប្រកាសលទ្ធផល**
4:00 - Announcements for the winners of this year's Boat Racing Contest/Closing remarks with Dahnie and Nita
4:15 - Ghla's Band
5:00 - End


## កម្មវិធីថៃសុខភាពតាមគេហដ្ឋានសម្រាប់ចាស់ៗ និងជនពិការភាព

- នាងថៃខ្ញុំដូចជាម្ដាយបង្កើត ខ្ញុំសប្បាយចិត្តណាស់
- នាងស្រឡាញ់និងថៃខ្ញុំដូចជីដូនបង្កើត
- នាងចំអិនម្ហូប បោសសំអាតផ្ទះ បោកខោអាវ ហើយស្ដាប់រឿងខ្ញុំពេលខ្ញុំកើតទុក្ខ
- ខ្ញុំមានពេទ្យមកពិនិត្យសុខភាពជាប្រចាំ
- នាងរលឹកពេលដែលខ្ញុំត្រូវញាំថ្នាំ គ្រប់ពេលវេលា
- នាងជូនខ្ញុំដើរលេងលំហែកាយ
- នាងជួយខ្ញុំទិញម្ហូបនិងសំភារៈប្រើប្រាស់
- កូនខ្ញុំមិនព្រួយអំពីភាពអត់ការងារធ្វើ ហើយបាននៅក្បែរខ្ញុំគ្រប់ពេលវេលា
- ព្រឹទ្ធាចារ្យជាដុំពេជ្យក្នុងសង្គមយើង ចូរអ្នកទាំងអស់ខំថៃទាំគាត់អោយមានអាយុវែងនិងសុខភាពល្អ។

ក្រុមហ៊ុនយើងខ្ញុំកំពុងជ្រើសរើសបុគ្គលិកធ្វើការ
សម្រាប់ពត៌មានបន្ថែមអំពីកម្មវិធីនេះសូមទាក់ទង

ម៉ូនីដា (២៦៧) ២៦២-៣៩២៩ ដេវីដ (២៦៧) ៩១៨-៨៤៩៣

HOME CARE
Aurora



# ការបញ្ចេញមតិដោយសេរីរបស់ពលរដ្ឋសំរាប់ការបោះឆ្នោត នៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣




ការបោះឆ្នោតនីតិកាលទី៣ ចាប់តាំងពីឆ្នាំ២០០៨ ដល់ឆ្នាំ ២០១៣ គណបក្សប្រជាជនកម្ពុជា ទទួលបាន៩០អាសនៈក្នុងចំណោម អាសនសរុបចំនួន១២៣។

នេះជាចំនួនសន្លឹកឆ្នោតដ៏ច្រើន សន្ទឹកសន្ធាប់ដែលប្រជាជនបាន បោះជូនគណបក្សប្រជាជនកម្ពុជា សំរាប់អណត្តិ៥ឆ្នាំ ដើម្បីសំរេចនូវជោគវាសនា របស់ប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលត្រូវបានបន្ត និងដឹកនាំដោយ សម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រីសំរាប់ អណត្តិទីបីជាបន្តបន្ទាប់។

សមិទ្ធផលជាច្រើនដែលរាជរដ្ឋាភិបាល សំរេចបានក្នុងនីតិកាលទី៣

ជាបឋមមានដូចជា ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន គ្រឹះស្ថានអប់រំ ក៏ដូចជា គំរោងសាងសង់វារីអគ្គីសនីចំនួន៦ និងរោងចក្រអគ្គីសនីចំនួន២ ដំណើរការដោយថាមពលធ្យូងថ្ម ប្រទេសកម្ពុជានឹងរំពឹងថា កំលាំងនៃថាមពលអគ្គីសនីនឹងមានសន្ទុះកើនឡើងបួនដងនៅឆ្នាំ២០២០។

ក្រៅពីនេះមានការកែច្នៃឡើងវិញនូវផ្លូវអយស្ម័យានចំនួន២ខ្សែដែលមានបណ្តោយប្រវែង ៦៥២គីឡូម៉ែត្រ ការអភិវឌ្ឍន៍នេះនឹងជួយបង្កើន និងបង្កភាពងាយស្រួលផ្នែកដឹកជញ្ជូនទំនិញតាមផ្លូវរថភ្លើងដោយសុវត្ថិភាព។

សេដ្ឋកិច្ចប្រទេសកម្ពុជាបានកើនឡើង៧ភាគរយក្នុងឆ្នាំ២០១២ តាមការស្រាវជ្រាវរបស់អង្គការមូលនិធិរូបិយប័ណ្ណអន្តរជាតិ IMF) ដែលផ្តល់ផលប្រយោជន៍ជាច្រើនលើគ្រប់វិស័យ ដូចជា វិស័យ វាយនភណ្ឌ វិស័យកសិកម? វិស័យសំណង់ និងទេសចរណ៍ជាដើម។

ទោះជាយ៉ាងណាការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលមិនបានបំពេញនូវសេចក្តីពេញចិត្តរបស់ប្រជាពលរដ្ឋទាំងស្រុងនោះទេ ។ យោងតាមប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រី "កុំមើលដើមឈើមួយដើមតែត្រូវមើលព្រៃទាំងមូល"លោកបានថ្លែងពាក្យមួយឃ្លានេះ ដើម្បីសម្តែងនូវប្រតិកម្មចំពោះលោក Moeung Sonn នាយកក្រុមហ៊ុនទេសចរណ៍ដែលក្រោយមកត្រូវបានបង្ខំនិរទេសខ្លួនទៅនៅស្រុកបារាំងវិញ។

លទ្ធផលបណ្តោះអាសន្ននៃសន្លឹកឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ បានបង្ហាញយើងនូវរូបភាពព្រៃឈើដែលមានរាងជាអក្សរ T" ៥៥ភាគរយ ជាព្រៃឈើដែលសេសសល់គ្រប ដណ្តប់ផ្ទៃដីគណបក្សប្រជាជនកម្ពុជាទទួលបាន ៦៨អាសនៈ ក្នុងចំណោមអាសនៈចំនួន១២៣) ចំណែក៤៥ភាគរយទៀត ជាព្រៃដែលស្ថិតក្រោមម្លប់ឈើគណបក្សសង្គ្រោះជាតិដែលហៅកាត់ថា NRCP ទទួលបាន៥៥អាសនៈក្នុងចំណោម១២៣ អាសនៈ)។ គោលបំណងនៃអត្ថបទនេះ គឺដើម្បីបង្ហាញនូវបុព្វហេតុនៃការបែងចែកអាសនៈ ដូចនេះ៤៥ភាគរយនៃព្រៃឈើនឹងបែកមែកសាខាត្រសុំ ត្រសាលបន្តទៀត។

ការខ្វះភាពជឿជាក់មួយចំនួនតូចដែលពាក់ពន្ធ័ទៅលើចំណាត់ការដោះស្រាយបញ្ហា និងភាពខ្វះចន្លោះនៅក្នុងកំណែទម្រង់ច្បាប់

១-ជាបឋមកត្តាដែលនាំមកនូវភាពទោមនស្សដល់ប្រជាជន គឺអំពើពុករលួយដែលរីករាលដាលពេញផ្ទៃប្រទេសបច្ចុប្បន្ន។ អំពើពុករលួយបានផ្តើមចេញពីអ្នកដែលមានតួនាទីសំខាន់ៗនៅក្នុងជួររដ្ឋាភិបាល និងបុគ្គលពាក់ព័ន្ធឃុបឃិតជាមួយគ្នាជាបណ្តាញបក្សពួកតែមួយរួមគ្នាបង្កើតជាទីផ្សារជំនួញក្នុងគោលបំណងបំរើផលប្រយោជន៍បុគ្គល។

-នៅតាមតំបន់មួយចំនួនសិស្សានុសិស្សនៅសាលារដ្ឋត្រូវបង្ខំចិត្តបង់លុយទៅឱ្យគ្រូបង្រៀនផ្ទាល់ ឬបង់ថ្លៃឯកសារនានាផ្សេងៗទៀត ។ល។ ដែលមិនតម្រូវឱ្យបង់ថ្លៃ

-ប្រជាជនត្រូវបង់លុយជូនអជ្ញាធររដ្ឋបាល ទោះបីជាតាមច្បាប់មិនតម្រូវឱ្យបង់ថ្លៃក៏ដោយ ក៏អជ្ញាធរទាំងនោះទាមទារថ្លៃសេវាផ្ទាល់ខ្លួន។

-បុគ្គលអ្នករំលោភច្បាប់ចរាចរណ៍បាន ចំណាយលុយឱ្យប៉ូលីស ដើម្បីបំបាត់ភស្តុតាង និងមិនចាំបាច់ទៅឆ្លើយបំភ្លឺនៅស្ថានីយ៍ប៉ូលីសនូវកំហុសឆ្គងដែលខ្លួនបានប្រព្រឹត្ត។

-នៅតាមគ្រឹះស្ថានថែទាំសុខភាពរបស់រដ្ឋនានា អ្នកសំរាកព្យាបាលត្រូវបង់លុយក្រៅទៅឱ្យបុគ្គលិកដែលពាក់ពន្ធ័ក្នុងការសំរាកព្យាបាល ទើបធានាបាននូវការយកចិត្តទុកដាក់តិច ឬច្រើន អាស្រ័យទៅលើទឹកប្រាក់ជាថ្នូរទោះបីស្ថិតក្នុងមន្ទីរពេទ្យតែមួយដូចគ្នា។

ប្រជាជនដែលមិនមានប្រាក់ និងអំណាច មិនអាចធ្វើការតវ៉ាបានត្រឹមតែទទួលស្គាល់នូវអ្វីដែលអជ្ញាធរកំណត់ឱ្យ។

រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដោយមិនមានការពិភាក្សាឱ្យបានម៉ត់ចត់ជាមុន និងមិនមានការធ្វើកំណែប្រែអ្វីឡើយ។

ច្បាប់ថ្មីនេះបានចូល តទៅទំព័រទី ១០






## តមកទំព័រទី ៨ ការបញ្ចេញមតិដោយសេរីរបស់ពលរដ្ឋ...

ជាធរមាននៅខែវិច្ឆិកាឆ្នាំ២០១០។ ជាលទ្ធផលច្បាប់នេះបានបង្កើតនូវអង្គភាពប្រឆាំងអំពើពុករលួយចំនួនពីរគឺៈ គណកម្មការជាតិប្រឆាំងអំពើរពុករលួយហៅកាត់ថា (National Anti-Corruption Commission NAC) ដែលទទួលខុសត្រូវទៅលើការអភិវឌ្ឍនីតិវិធានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាព -នៅថ្នាក់ជាតិ និងជាអង្គភាពប្រឆាំងអំពើរពុករលួយ (Anti unit Corruption Unit- ACU) នៅក្រុមប្រឹក្សា គណៈរដ្ឋមន្ត្រីដែលធ្វើការស៊ើបអង្កេតទៅលើអ្នកជាប់ពាក់ពន្ធ័អំពើរពុករលួយនៅក្នុងជួររាជរដ្ឋាភិបាល FIDH - ខែវិច្ឆិកា ឆ្នាំ២០១០)។

នៅក្នុងក្រសែភ្នែករបស់សាធារណៈជនដែលបានធ្វើការវាយតម្លៃទៅលើវិធានការប្រឆាំងអំពើពុករលួយទាំងនេះថា មានភាពខ្វះខាតជាច្រើនដោយសកម្មភាពរបស់គ្រឹះស្ថានទាំងនេះនៅទន់ខ្សោយនៅឡើយ និងមិនអាចជួយដល់ការរស់នៅរបស់ប្រជាជនឱ្យមានភាពប្រសើរឡើងបាន។

២-កត្តាទីពីរ គឺប្រពន្ធ័តុលាការដែលទទួលរងនូវភាពរិះគន់។ ភាពលើកលែងទោសតែងកើតមានចំពោះជនប្រើប្រាស់អាវុធខុសច្បាប់ និងបុគ្គលដែលមានអំណាចដែលពួកគេមិនគោរពច្បាប់។ ជាក់ស្តែងមានរឿងមួយក្នុងចំណោមរឿងជាច្រើនអនេកដែលបានកើតមានៈ នៅខែមករាកន្លងទៅថ្មីៗមានកម្មករកម្មការិនីជាង១ពាន់នាក់នៃរោងចក្រកាត់ដេរ Manhattan Special Economic Zone បានធ្វើបាតុកម្មដើម្បីទាមទារកែប្រែលក្ខណ្ឌការងារឱ្យបានប្រសើរ មានបុរសម្នាក់ប្រដាប់ដោយអាវុធបានធ្វើការបាញ់ទៅលើហ្វូងបាតុកររួចជិះម៉ូតូគេចខ្លួនដោយសុវត្ថិភាពដោយបន្សល់ទុកនូវកម្មករក្មេងៗឱ្យរងរបួសជាទម្ងន់ ។ តាមការអះអាងរបស់លោកចៅសង្កាត់នៅតំបន់នោះថា បុរសប្រដាប់ដោយអាវុធនោះ ត្រូវបានជាប់ចោទពីបទបង្ករបួសស្នាមដោយអចេតនាដោយមិនត្រូវបានចាប់ខ្លួននៅឡើយ។

ជនប្រព្រឹត្តបទល្មើសដែលត្រូវជាប់ទោសជារឿយៗត្រូវបានរួចខ្លួនពីសំណាញ់ច្បាប់ Mc Gill- ខែកក្កដា ឆ្នាំ២០១២)។

យុត្តិធម៌កើតមានសំរាប់អ្នកមានទ្រព្យធន់។ នេះជារឿងមួយៈ មនុស្សម្នាក់បានទិញផ្ទះល្វែងមួយនៅជាន់ទីបី ហើយបានសុំការអនុញ្ញាតិពីអជ្ញាធរ ដើម្បីធ្វើការកែរលំអរផ្ទះល្វែងនេះ។ អ្នកជិតខាងដែលនៅផ្ទះជាន់ក្រោមបានស្នើឱ្យត្រួតពិនិត្យបញ្ហាជ្រាបទឹក។ ថ្ងៃមួយអ្នកជិតខាងនេះបានចាក់សោរដោយបង្ខាំងកម្មករជាប់ក្នុងផ្ទះ។ ម្ចាស់ផ្ទះក៏បានរាយការណ៍ទៅប៉ូលីសពីបញ្ហានេះ បន្ទាប់ពីមានការអន្តរាគមន៍រួចរាល់ហើយ ប៉ូលីសបានដោះលែងកម្មករដែលជាប់សោរនៅខាងក្នុងទាំងនោះឱ្យរួចខ្លួនឡើងវិញ។

ក-ម្ចាស់ផ្ទះល្វែងបានដាក់ពាក្យបណ្តឹង។ ពាក្យបណ្តឹងត្រូវបានកប់នៅក្រោមគំនរឯកសារជាច្រើន ដែលមិនទាន់បានដោះស្រាយ។

ខ-អ្នកជិតខាងបានប្តឹងពីការដែលខូចខាតអាគារក្រោយមកក៏ត្រូវបានកោះហៅទៅតុលាការដើម្បីសួរចម្លើយ។

គ-ជនជាប់ចោទត្រូវបានរួចខ្លួនពីការចោទប្រកាន់ដោយសារទំនាក់ទំនង និងការចំណាយប្រាក់។

ឃ-អ្នកជិតខាងនោះក៏បានដាក់ពាក្យបណ្តឹងម្តងទៀត

ង-ឯកសារដែលម្ចាស់ផ្ទះបានដាក់ពាក្យបណ្តឹងមិនត្រូវបានដោះស្រាយឡើយ ព្រោះគ្មានប្រាក់គ្រប់គ្រាន់។ ហេតុនេះបើគ្មានប្រាក់ពាក្យបណ្តឹងមិនត្រូវបានគេលើកយកមកដោះស្រាយ និងមិនអាចស្វែងរកយុត្តិធម៌បានឡើយ។ មិនមានកំណែទម្រង់ផ្តួចផ្តើមដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពវិនិច្ឆ័យតាមផ្លូវច្បាប់នៅឡើយ។ បុគ្គលដែលគ្មានលុយ និងគ្មានទំនាក់ទំនង គឺជាជនរងគ្រោះ ។

៣-កត្តាទី៣ គឺបញ្ហាធនធានមនុស្សដែលគួរផ្តោតការយកចិត្តទុកដាក់ដល់យុវជនក្មេងៗដែលកំពុងជួបវិបត្តិគ្មានការងារធ្វើលោកនាយករដ្ឋមន្ត្រីតែងតែអញ្ជើញចូលរួមអបអរសាទរនៅពេលបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ។ ប៉ុន្តែនេះមិនមែនជាជោគជ័យពិតប្រាកដសំរាប់យុវជនឡើយ ព្រោះសញ្ញាប័ត្រគ្រាន់តែជាក្រដាសមួយសន្លឹក ប៉ុន្តែចំណេះដឹងជារឿងសំខាន់ ហើយតើរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ និងមានវិធានការយ៉ាងណាដើម្បីជួយដល់យុវជនក្មេងៗដែលមានតែសញ្ញាប័ត្រ ប៉ុន្តែចំណេះដឹងមិនអាចប្រកួតប្រជែងក្នុងទីផ្សារការងារបាន។

ប្រជាជនជាង១៤លាននាក់ ប្រមាណជាង៥៥ភាគរយ គឺជាយុវជនក្រោមអាយុ២៥ឆ្នាំ ។ រដ្ឋាភិបាលបានខិតខំដោះស្រាយបញ្ហាជំលោះព្រំដែនជាមួយប្រទេសជិតខាង - ចូលរួមក្នុងកិច្ចការសហការជាមួយអាស៊ានជាដើម ។ល។

ជាក់ស្តែងដូចជា ការបិទកន្លែងខារ៉ាអូខេ -ការក្លែងបន្លំផ្លាកដែលជាកម្មសិទ្ធិរបស់រដ្ឋដាក់ជារបស់បុគ្គលឯកជន -ការកាប់បំផ្លាញព្រៃឈើខុសច្បាប់ត្រូវបានកាត់បន្ថយ ។ ប៉ុន្តែនេះមិនមែនជាស្ថានភាពត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនោះទេ ព្រោះស្ថាប័នពាក់ពន្ធ័មិនបានបង្ហាញនូវសុទិដ្ឋិនិយមក្នុងការត្រួតពិនិត្យ និងដោះស្រាយបញ្ហាឱ្យបានពេញលេញឡើយ។ ការខ្វះចន្លោះទាំងនោះគួរមានការចូលរួមដោះស្រាយពីគណបក្សម្ខាងទៀត ដើម្បីទទួលបានសំលេងគាំទ្រនៅអណត្តិក្រោយទៀត។

សូមរដ្ឋាភិបាលអណត្តិថ្មីស្វែងរកនូវដំណោះស្រាយសំរាប់បញ្ហាដែលបានរៀបរាប់ខាងលើ។ សូមជូនពរគ្រប់ថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ប្រកបដោយជោគជ័យក្នុងគោលបំណងបំរើផលប្រយោជន៍ជាតិ និងនិរន្តរភាពនៃប្រទេសកម្ពុជា។

ភ្នំពេញ ថ្ងៃទី១ ខែសីហា ឆ្នាំ ២០១៣

Songthoul FERNANDEZ


# Lowell Community Health Center

161 Jackson Street, Lowell, MA 01852

## Caring for Lowell

Lowell Community Health Center provides professional health care services to the people of Greater Lowell. The Health Center's caring staff speak Khmer and many other languages. We accept all forms of health insurance, and we can help you apply for insurance coverage for your medical care. Services include:

- Doctor's Visits
- Behavioral Health Counseling
- Social Services
- Traditional healing, acupuncture, massage therapy

LOWELL COMMUNITY HEALTH CENTER

Accepting New Patients

មណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលផ្តល់ជូននូវសេវាសុខភាពដោយអ្នកមានជំនាញច្បាស់លាស់ទៅដល់ប្រជាជនទូទៅដែលរស់នៅក្នុងតំបន់ឡូវែល ។ យើងមានបុគ្គលិកថែទាំសុខភាព ដែលនិយាយភាសាខ្មែរ និងភាសាផ្សេងៗទៀត ។ យើងក៏អាចជួយលោកអ្នក ក្នុងការដាក់ពាក្យសុំការធានាសុខភាព សម្រាប់សេវាថែទាំសុខភាពលោកអ្នកផងដែរ ។ សេវាថែទាំសុខភាពរួមមាន :

- ការពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត
- ការប្រឹក្សាអំពីសុខភាពផ្នែកអារម្មណ៍ និងផ្លូវចិត្ត
- សេវាសង្គម
- ការព្យាបាលបែបបុរាណ បែបចាក់ម្ជុលវិទ្យាសាស្ត្រ បែបម៉ាសាធ្វើសរសៃ

Services in English & Khmer



Join Our Team. Now Hiring!

## Work at Lowell Community Health Center

The Health Center offers rewarding career opportunities to medical and behavioral health professionals and support staff. Visit our website to learn more about joining our diverse team.

មណ្ឌលសុខភាពកំពុងផ្តល់ឱកាសដល់ពេទ្យផ្នែកព្យាបាល ពេទ្យជំនាញផ្នែកអារម្មណ៍ និងផ្លូវចិត្ត និងបុគ្គលិកថែទាំសុខភាព ។ សូមចូលទៅកាន់គេហទំព័រ www.lchealth.org ដើម្បីស្វែងយល់ពីរបៀបចូលរួមជាមួយក្រុមដែលមានលក្ខណ:សំបូរបែបនេះ ។

978-221-6777

www.lchealth.org

# ភ័ព្វសំណាងដែលប្រជាពលរដ្ឋខ្មែរត្រូវតែចាប់យក

**លិម តិមយ៉ា**
*តំណាងរាស្ត្រគណបក្ស សង្គ្រោះជាតិនៅខេត្តកំពង់ធំ*



កាលពីឆ្នាំ១៩៧៥របបកុម្មុយនិសបានទទួលជោគជ័យដោយសង្គ្រាមនៅប្រទេសទាំងពីរ គឺប្រទេសខ្មែរ និងយួនខាងត្បូងក្រោយពីទ័ពសហរដ្ឋអា-មេរិកដកចេញដោយគោរពទៅតាមសន្ធិសញ្ញាឈប់ច្បាំងកាលពីថ្ងៃទី២៧មករា១៩៧៣ រវាងអាមេរិកសាធារណរដ្ឋយួនខាងជើងសាធារណរដ្ឋយួនខាងត្បូង និងរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នសាធារណរដ្ឋយួនខាងត្បូងដែលគេហៅថាយៀកកុងនោះ។

សាធារណរដ្ឋយួនខាងជើងមិនបានគោរពសន្ធិសញ្ញានេះទេ។ យួនខាងជើងបានលើកទ័ពមកវាយយួនខាងត្បូងក្រោយពីការដកទ័ពអាមេរិកាំងចេញ ។ ហើយយួនខាងជើង និងយៀកកុងបានយកជ័យជំនះលើយួនខាងត្បូងដោយចូលព្រៃនគរដែលហៅសព្វថ្ងៃក្រុងហូជីមិញកាលពីថ្ងៃទី៣០មេសា១៩៧៥ ។ ឯចំណែកខ្មែរក្រហមបានយកជ័យជំនះចូលភ្នំពេញកាលពីថ្ងៃទី១៧ មេសា ១៩៧៥ ។

នៅពេលពួកកុម្មុយនិសទាំងពីរនេះចូលមកកាន់អំណាចភ្លាមប្រជាពលរដ្ឋទាំងពីរប្រទេសខ្មែរ និងយួនភ័យស្លន់ស្លោនាំគ្នារត់ភៀសខ្លួនចោលស្រុករាប់សែននាក់ ហើយជាច្រើនបាត់បង់ជីវិតតាមសមុទ្រជាន់មីនសំលាប់ដោយពួកប្រដាប់អាវុធកុម្មុយនិស។

ការភ័យស្លន់ស្លោនេះជាការត្រឹមត្រូវពីព្រោះពួកកុម្មុយនីស្តទាំងពីរនេះរំលោភលើសិទ្ធិប្រជាពលរដ្ឋគ្រប់បែបយ៉ាង ។ បើគិតពីចំនួនជនរងគ្រោះដល់ជីវិតក្នុងរយៈពេលដែលពួកកុម្មុយនីស្តទាំងពីរនេះកាន់អំណាចរហូតមកដល់សព្វថ្ងៃឃើញថាចំនួនជាច្រើនលាននាក់។

នៅពេលជាមួយគ្នានោះ ពួកអ្នកដឹកនាំយួនខាងជើងមិនត្រឹមតែក្បត់នឹងសហមិត្តអាវុធយៀកកុងនោះទេ ដែលសន្យាថា ព្រមឱ្យមានស្វ័យភាពដល់ជនជាតិគេពួកអ្នកដឹកនាំយួនខាងជើងបានចាប់ និងសំលាប់អ្នកដឹកនាំយៀកកុងទាំងអស់លើកលែងតែខ្លះសុខចិត្តចូលបំរើគេដោយអត់ហ៊ានតវ៉ាឯអ្នកផ្សេងទៀតត្រូវរត់ចោលស្រុកជាប់គុកឬស្លាប់ ។ អ្នកដឹកនាំយៀកកុងអស់នេះភាគច្រើនជាជនជាតិភាគតិចរស់នៅលើតំបន់យួនខាងត្បូងដែលមិនមែនជាជនជាតិយួនដូចពួកនៅខាងជើងដោយប្រទេសយួនមានជនជាតិទៅដល់៥៤។

ក្នុងចំណោមទាំងជនជាតិ៥៤នោះដែលចែកទៅតាមក្រុមដែលមានដើមកំណើតភាសា៥និយាយមិនដូចគ្នា ។ មាន២១ក្រុមជនជាតិដែលភាសាដើមជាខ្មែរ( ប្រហែលជា២១ខេត្តខ្មែរដែលយួនវាយកហើយវាចែកជាជនជាតិទៅតាមខេត្ត) (១) ។ ហេតុនេះហើយបានជាយើងសង្កេតឃើញអាណិកជនយួនរស់នៅស្រុកខ្មែរសព្វថ្ងៃនិយាយខ្មែរច្បាស់ជាងពួកយួននៅមុនឆ្នាំ១៩៧០។ បានសេចក្តីថា ពួកអាណិកជនយួនរស់នៅស្រុកខ្មែរសព្វថ្ងៃ គឺជាជនជាតិដែលមានភាសាដើមជាខ្មែរ និងចាមដែលរស់នៅតាមទល់ដែន និងខាងត្បូងស្រុកយួន។

គង់តែសព្វថ្ងៃនេះក៏ដោយក៏ប្រជាពលរដ្ឋប្រទេសទាំងពីរនេះរកមធ្យោបាយរត់ចេញពីប្រទេសទៅរស់នៅប្រទេសក្រៅដោយមានឋានៈនិងងារត្រឹមណាក៏ដោយដោយយល់ថា ប្រទេសទាំងពីរនេះគ្មានអនាគតសោះឡើយ(២) ។ការដែលយល់យ៉ាងដូច្នេះ ពីព្រោះពួកកុម្មុយនីស្តកាន់អំណាចហើយពួកអស់នេះកាន់អំណាចតាំងពីជិត៤០ឆ្នាំមកហើយគ្រាន់តែនៅប្រទេសខ្មែរដូរតែអ្នកដឹកនាំពីពួក ប៉ុល ពត. មក ហេង សំរិន. ជាស៊ីម . និង ហ៊ុន សែន តែប៉ុណ្ណោះដែលដឹកនាំគណបក្សប្រជាជន។

កាលពីឆ្នាំ២០១១គណបក្សប្រជាជនហៅ "ប្រជ" បានធ្វើបុណ្យរំឭកខួបឆ្នាំ៦០ពីកំណើតបក្សនេះនៅឆ្នាំ១៩៥១។ ឃើញថា គណបក្សប្រជាជនហៅ"ប្រជ"នៅតែកាន់លិទ្ធិកុម្មុយនីស្តដដែលគង់តែនៅប្រទេសខ្មែរមានរដ្ឋធម្មនុញ្ញជាសេរីក៏ដោយដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា១៩៩៣។

រដ្ឋធម្មនុញ្ញនេះកើតឡើងក្រោយពីពេលបោះឆ្នោតឆ្នាំ១៩៩៣បន្ទាប់ពីសន្ធិសញ្ញាទីក្រុងប៉ារីសកាលពីទី២៣តុលា១៩៩១។ សហគមអន្តរជាតិបានសំរេចជួយធានាដល់ប្រទេសខ្មែរឱ្យមានសន្តិភាពគោរពសិទ្ធិមនុស្ស និងការពារបូរណភាពទឹកដីក្រោយពីប្រទេសខ្មែរទទួលរងទុក្ខវេទនាដែលគ្មានអ្វីប្រៀបបាន និងក្រោមការត្រួតត្រាពីសំណាក់យួន ។

ក្រោយពីសោកនាដកម្មនេះប្រជាពលរដ្ឋខ្មែរមានភ័ព្វសំណាងដោយមានការធានាអះអាងពីសហគមអន្តរជាតិអាចនឹងជ្រើសរើសអ្នកដឹកនាំខ្លួនដោយសេរីបាន។ ឯចំណែកប្រជាពលរដ្ឋយួនគ្មានវាសនាដូចប្រជាពលរដ្ឋខ្មែរទេ ដែលគេមិនអាចជ្រើសរើសអ្នកដឹកនាំដោយសេរីបានសេចក្តីថា ប្រជាពលរដ្ឋយួនរស់នៅក្រោមនឹមលិទ្ធិកុម្មុយនីស្តទៅអនាគតដែលមិនដឹងជាថ្ងៃណាមួយនឹងគេចផុតទេគង់តែប្រជាពលរដ្ឋយួនស្អប់ខ្ពើមអ្នកដឹកនាំខ្លួនយ៉ាងដូចម្តេចក៏ដោយ ។

ហេតុដូច្នេះហើយប្រជាពលរដ្ឋទាំងអស់នៅប្រទេសខ្មែរត្រូវតែចាប់ឱ្យជាប់កុំឱ្យភ័ព្វសំណាងដ៏ល្អ និងដ៏សំខាន់នេះគេចផុតទៀត ដូចនៅពេលមុនៗដោយចាញ់បោកការកុហករបស់គណបក្សកុម្មុយនីស្តប្រជាជនហៅ "ប្រជ"ដែលគេកុហកនិងសំឡុត។ ត្រូវយើងដឹងថា គណបក្សប្រជាជនហៅ "ប្រជ" ជាគណបក្សកុម្មុយនីស្តហេតុនេះរបៀបត្រួតស្រុកក៏ជាកុម្មុយនីស្ត គឺរំលោភលើសិទ្ធិប្រជាពលរដ្ឋដែលគេសង្កេតឃើញគ្រប់វេលារហូតដល់សហគមអន្តរជាតិតាមរយៈអ្នកតំណាងរបស់គេតែងតែរំឭកពីការរំលោភលើការសន្យារបស់រាជរដ្ឋាភិបាលនៅក្នុងសន្ធិសញ្ញាទីក្រុងប៉ារីសស្តីអំពីសិទ្ធិមនុស្ស៕

**លោកអ្នកចង់រកប្រាក់ចំណូលបន្ថែមដែរ ឬទេ?**

$ យើងអាចជួយលោកអ្នកចំនួន១៥នាក់ ក្នុងការរកប្រាក់ចំណូលបាន៥ពាន់ដុល្លារក្នុង១ខែ និងមនុស្ស៥០នាក់ឲ្យរកប្រាក់ចំណូលពី$៥០០ទៅ $១០០០ក្នុងមួយខែ ។ $

ជាការងារក្រៅម៉ោង ។ អាយុ១៨ឆ្នាំឡើងទៅ ។

**ព័ត៏មានបន្ថែមតាមទូរស័ព្ទ**

(ភាសាខ្មែរ ) ធីន : ៨៦០-៦៥៥-៤៥៩៩

(ភាសាអង់គ្លេស )ដូឡាស : ៥០៨-២៤៦-៩០២១



ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទនេះកម្រង់ និងទទួលការអនុញ្ញាតឲ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សុក្រ ទី២៦ ខែកក្កដា ឆ្នាំ២០១៣

# លោក ស ខេង ព្រមានថា នឹងមានបញ្ហា ប្រសិនបើការចរចាជាប់គាំង

**ហ៊ុល រស្មី**
**ខេមបូឌា ដេលី**

កាលពីម្សិលមិញលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានព្រមានថា នឹងមាន"បញ្ហា" ប្រសិនបើលោក សម រង្ស៊ី មេដឹកនាំគណបក្សសង្គ្រោះជាតិមិនវិលទៅតុចរចា ដើម្បីស្វែងរកដំណោះស្រាយចំពោះការជាប់គាំងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សប្រឆាំងជុំវិញភាពមិនប្រក្រតីអំឡុងការបោះឆ្នោតជាតិ កាលពីថ្ងៃទី២៨ ខែកក្កដាទេនោះ ។

លោក ស ខេង បានធ្វើការអត្ថាធិប្បាយបែបនេះបន្ទាប់ពីលោកបានជួបជាមួយឯកអគ្គរដ្ឋទូតបារាំង និងអាល្លឺម៉ង់ជាលក្ខណៈឯកជន និងដាច់ដោយឡែកពីគ្នាកាលពីម្សិលមិញ និងបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតហៅកាត់ថា គជប បានលើកឡើងកាលពីថ្ងៃអាទិត្យថា គម្រោងឱ្យមានគណៈកម្មាធិការមួយដែលមានគណបក្សចម្រុះចូលរួម ដើម្បីស៊ើបអង្កេតភាពមិនប្រក្រតីអំឡុងពេលបោះឆ្នោតត្រូវបានបោះបង់ចោល ។

គណបក្សសង្គ្រោះជាតិដែលបានអះអាងថាខ្លួនក៏ជាអ្នកទទួលជ័យជំនះនៅក្នុងការបោះឆ្នោតដែរនោះ កំពុងទាមទារឱ្យអង្គការសហប្រជាជាតិចូលរួមពាក់ព័ន្ធនៅក្នុងគណៈកម្មាធិការណាមួយដើម្បីស៊ើបអង្កេតលើអ្វីដែលខ្លួនលើកឡើងថាជាភាពមិនប្រក្រតីដែលកើតមានគ្រប់ទីកន្លែងនៅក្នុងថ្ងៃបោះឆ្នោតជាលក្ខខណ្ឌមួយដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបដិសេធមិនព្រមធ្វើតាម ។

កាលពីម្សិលមិញលោក ស ខេង បានគាំទ្រសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ លោកបានមានប្រសាសន៍នៅក្រសួងមហាផ្ទៃដោយមានមន្ត្រីអមសងខាងថា "ខ្ញុំបានចរចាជាមួយលោក សម រង្ស៊ី តាមទូរស័ព្ទ ហើយបានប្រាប់គាត់ថា ប្រសិនបើយើងច្រានចោលយន្តការដែលមានប្រាប់របស់ គជប ហើយព្យាយាមស្វែងរកយន្តការមួយផ្សេងទៀតនោះ និងមានបញ្ហាកាន់តែច្រើន" ។

លោកបានមានប្រសាសន៍ទៀតថា "គ្មានលក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យអ្នកនេះ ឬអ្នកនោះចូលរួមឡើយ" ។

លោក ស ខេង មិនបានមានប្រសាសន៍លម្អិតថា "បញ្ហា"ដែលលោកសំដៅនោះជាអ្វីទេ ប៉ុន្តែមានប្រសាសន៍ទៀតថា ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាអាចនឹងរងផលប៉ះពាល់ដោយសារស្ថានភាពជាប់គាំងនាពេលបច្ចុប្បន្ន ។

លោក ស ខេង ក៏បានមានប្រសាសន៍ដែរថា គណបក្សសង្គ្រោះជាតិចាំបាច់ត្រូវមានការប្រុងប្រយ័ត្នចំពោះការធ្វើឱ្យបាត់បង់សន្តិភាព ហើយមានប្រសាសន៍ថា បាតុកម្មណាមួយត្រូវធ្វើឱ្យប្រាកដថា "ប្រជាពលរដ្ឋអាចរស់នៅក្នុងសន្តិភាព គម្រោងវិនិយោគនានា និងការអភិវឌ្ឍន៍សង្គមនឹងនៅតែដំណើរការជាធម្មតា" ។

លោកបានមានប្រសាសន៍ថា ជំនួបរបស់លោកជាមួយអគ្គរដ្ឋទូតទាំងពីរបានផ្ដោតជាសំខាន់លើ "ភាពមិនប្រក្រតីក្នុងការបោះឆ្នោត និងសន្តិភាពសុខសង្គម បន្ទាប់ពីការបោះឆ្នោតកាលពីខែមុន" ។

នៅក្នុងអ៊ីម៉ែលដាច់ដោយឡែកពីគ្នាលោក វ៉ូល ហ្គាំង ម៉ូស័រ (Wolfgang Moser) អគ្គរដ្ឋទូតអាល្លឺម៉ង់ និងលោក នីកូ ឡាស ប៊ូឌុង (Nicolas Baudouin) លេខាទី១ នៃស្ថានទូតបារាំងបានលើកឡើងថា ពួកលោកមិនអាចធ្វើអត្ថាធិប្បាយអំពីខ្លឹមសារនៃជំនួបរបស់ខ្លួនជាមួយរដ្ឋមន្ត្រីរូបនេះបានទេ ។

នេះមិនមែនជាលើកទី១ទេ ដែលមន្ត្រីជាន់ខ្ពស់របស់គណបក្សកាន់អំណាចបាននិយាយបញ្ឆិតបញ្ឆៀងអំពីលទ្ធភាពនៃអស្ថិរភាពនៅក្រោយថ្ងៃចេញលទ្ធផលបោះឆ្នោត ។

នៅមុនការបោះឆ្នោតលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានម្ដងហើយម្ដងទៀត អំពីការវិលទៅរកសង្គ្រាមស៊ីវិល ឬយុគសម័យមួយដែលស្រដៀងគ្នាទៅនឹងរបបខ្មែរក្រហម ប្រសិនបើគណបក្សរបស់លោកដែលបានកាន់អំណាចជាយូរមកហើយនោះចាញ់ឆ្នោត ។ បន្ទាប់ពីគណបក្សរបស់លោកបានទទួលជ័យជំនះនៅក្នុងការបោះឆ្នោតជាតិកាលពីថ្ងៃទី២៨ ខែកក្កដា ជាដំបូងលោក ហ៊ុន សែន ទំនងជាមានឥរិយាបថសម្រុះសម្រួល ប៉ុន្តែកាលពីថ្ងៃសុក្រលោកបានព្រមានជាថ្មីម្ដងទៀតថា នឹងមានភាពចលាចលខ្លាំងក្នុងសង្គមនៅក្នុងរាជធានីភ្នំពេញ ប្រសិនបើគណបក្សប្រឆាំងធ្វើបាតុកម្មជាសាធារណៈ ។

លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា គណបក្សរបស់លោកបានអះអាងថា ការគោរពច្បាប់ គឺសំខាន់ជាងអ្វីទាំងអស់ចំពោះគណបក្សលោក ។

លោក យឹម សុវណ្ណ បានមានប្រសាសន៍ទៀតថា "អ្វីដែល **តទៅទំព័រទី ២០**

# Sar Kheng Warns of 'Trouble' if Negotiations Stall

*By Hul Reaksmey - August 6, 2013*

Interior Minister Sar Kheng on Monday warned of "trouble" if opposition leader Sam Rainsy does not return to the negotiating table to hammer out a solution to a stalemate between the CPP and the opposition over irregularities during the July 28 national election.

Mr. Kheng made his comments after he met privately and separately on Monday with the French and German ambassadors, and after the National Election Committee (NEC) said on Sunday that plans for an inter-party committee to investigate alleged election irregularities had been abandoned.

Interior Minister Sar Kheng speaks to reporters Monday, warning of 'trouble' if the CNRP refuses to negotiate over a probe into election irregularities. (Siv Channa)

Interior Minister Sar Kheng speaks to reporters Monday, warning of 'trouble' if the CNRP refuses to negotiate over a probe into election irregularities. (Siv Channa)

The CNRP, which also claims it won the election, is insisting on U.N. involvement in any committee looking into what they say was widespread electoral irregularities, a condition the NEC has refused to meet.

Mr. Kheng on Monday backed the NEC in their decision.

"I had a dialogue with Sam Rainsy by telephone, and told him that if we kicked out the NEC's existing mechanism and tried to find an alternative, there would be more trouble," Mr. Kheng said, flanked by officials at the Interior Ministry.

"There is no necessary condition requiring the participation of this or that person," he said.

Mr. Kheng did not elaborate as to what "trouble" he was referring to, but added that the country's national development could be adversely affected by the current standoff.

Mr. Kheng also said that the CNRP needs to be mindful of upsetting the peace, and that any demonstrations must ensure "that people can live in harmony and that investment projects and social development will run as normal."

His meetings with the two ambassadors had centered on "election irregularities and social security after last month's election," he said.

In separate emails, German Ambassador Wolfgang Moser and French First Secretary Nicolas Baudouin said they could not comment on the content of their meetings with the minister.

It is not the first time that a high-ranking member of the ruling party has alluded to the possibility of instability in the wake of election results.

Prior to the election, Prime Minister Hun Sen repeatedly warned of a return to civil war or an era resembling the Khmer Rouge period if his long-ruling party should lose. After his party took a thumping at the polls on July 28, Mr. Hun Sen at first appeared conciliatory, but on Friday warned again of severe social chaos in Phnom Penh should the opposition demonstrate publicly.

CNRP spokesman Yim Sovann said his party had no intention of creating instability and insisted that following the law was of paramount importance to his party.

"What we have done is follow the law," Mr. Sovann said. "We have done nothing against the law. Anybody who wants to recreate the Khmer Rouge regime is a criminal. The words that intimidate people should be avoided," he said.

"Let the people judge—he [Mr. Kheng] shouldn't talk about that—he is in charge of security, and he has the means to do it peacefully…. You control the Ministry of Interior, so you are responsible for anything that occurs during demonstrations."

Protests, however, are a last resort for the CNRP, Mr. Sovann added.

The NEC issued its own statement pertaining to security concerns Monday, calling for the public not to listen to NGOs or the media until an official election result is reached.

"The dissemination of untrue information could confuse the public, which would spoil the environment and affect the social and security orders," it said.

The CPP was the first to announce an election result, claiming that it had won the election with 68 seats to 55 seats for the opposition CNRP at 7:40 p.m. on the night of the election.

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណើចប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សុក្រ ទី២៦ ខែកក្កដា ឆ្នាំ២០១៣

# គណបក្សសង្គ្រោះជាតិដាក់ពាក្យបណ្តឹង

## រាប់ពាន់ករណីទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

Matt Blomberg និង ម៉ិច ដារ៉ា

ខេមបូឌា ដេលី

គណបក្សសង្គ្រោះជាតិនឹងដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គជប នូវអ្វីដែលខ្លួនបានរកឃើញពីកិច្ចប្រឹងប្រែងប្រមូលពាក្យបណ្តឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងថ្ងៃបោះឆ្នោតដែលគណបក្សនេះបានទទួលយ៉ាងហោចណាស់ចំនួន១៨.៤០០ករណី ប៉ុន្តែជឿថាតួលេខនេះតំណាងតែមួយផ្នែកនៃភាពមិនប្រក្រតីក្នុងថ្ងៃបោះឆ្នោតប៉ុណ្ណោះ ។

មន្ត្រីគណបក្សសង្គ្រោះជាតិនៅរាជធានីភ្នំពេញដែលមានពាក្យបណ្តឹងចំនួន២.០០០ករណីត្រូវបានរាយការណ៍កាលពីថ្ងៃសុក្រ ហើយនៅខេត្តព្រៃវែង សៀមរាប បាត់ដំបង កំពង់ចាម កណ្តាល និងខេត្តក្រចេះ បានឱ្យដឹងថា ទោះបីជាប្រជាពលរដ្ឋជាច្រើនបានដាក់ពាក្យបណ្តឹងក៏ដោយ ក៏ប្រជាពលរដ្ឋខ្លះទៀត ត្រូវបានគេរាំងមិនឱ្យប្តឹងដែរ ដោយមានការភ័យខ្លាចអាជ្ញាធរមូលដ្ឋាន។

លោក ម៉ៅ មុនីវណ្ណ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិប្រចាំខេត្តកំពង់ចាមបានប៉ាន់ប្រមាណកាលពីយប់មិញថា លោកបានប្រមូលពាក្យបណ្តឹងចំនួន១០.០០០ករណីពីប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញពីការិយាល័យបោះឆ្នោត ។

លោកបានមានប្រសាសន៍ថា "នេះជាខេត្តមួយធំមានឃុំ-សង្កាត់ច្រើន ។ យើងមានប្រហែល១០.០០០ករណីត្រូវរាយការណ៍ទៅទីស្នាក់ការគណបក្សនៅរាជធានីភ្នំពេញ" ។

លោកស្រី កែ សុវណ្ណរត្ន័ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិប្រចាំខេត្តសៀមរាបបានរាយការណ៍ថា ប្រជាពលរដ្ឋដែលបាត់បង់សិទ្ធិបោះឆ្នោតជាច្រើននាក់មានការភ័យខ្លាចមិនហ៊ានដាក់ពាក្យបណ្តឹងបន្ថែមពីលើចំនួន៥០០ករណីប្តឹងមកគណបក្ស។

លោកស្រីមានប្រសាសន៍បន្តថា "ប្រជាពលរដ្ឋជាច្រើន បានបញ្ជាក់ជាមួយយើងថា ពួកគាត់អាចផ្តល់ភ័ស្តុតាងពីភាពមិនប្រក្រតីក្នុងថ្ងៃបោះឆ្នោតបាន ប៉ុន្តែបន្ទាប់ពីត្រូវបានគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋាននោះ ពួកគាត់មិនបានផ្តល់ហត្ថលេខារបស់ពួកគាត់ទេ ដោយសារពួកគាត់ព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួន"។

លោក ខូយ ស៊ីនឿន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិប្រចាំខេត្តបាត់ដំបងដែលបានធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀត ដើម្បីប្រមូលពាក្យបណ្តឹងនោះ មានប្រសាសន៍ថា លោកប្រមូលបានពាក្យបណ្តឹងសរុបចំនួន១.៧០០ករណី ។

លោកបានមានប្រសាសន៍បន្តថា "យើងបានរកឃើញថា ប្រជាពលរដ្ឋចំនួន១.២៨៧នាក់មិនមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៅថ្ងៃបោះឆ្នោត ហើយប្រជាពលរដ្ឋចំនួន១៨១នាក់ ឈ្មោះរបស់ពួកគាត់ត្រូវបានគេបោះឆ្នោតជំនួស ហើយប្រជាពលរដ្ឋចំនួន២៣៧នាក់ទៀតមិនអាចបោះឆ្នោតបានទេ ដោយសារឯកសារអត្តសញ្ញាណប័ណ្ណរបស់ពួកគាត់មិនត្រូវគ្នានឹងឯកសាររបស់ គជប ។

លោកបានមានប្រសាសន៍បន្តថា "យើងបានទៅជួបប្រជាពលរដ្ឋទាំងនោះ ដើម្បីធ្វើឱ្យពួកគាត់មានអារម្មណ៍ថា មានសុវត្ថិភាពក្នុងការរាយការណ៍ ប៉ុន្តែនៅទីនោះតែងតែមានវត្តមាននគរបាលម្នាក់នៅក្បែរប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋជាច្រើនទៀតមានការភ័យខ្លាចក្នុងការផ្តល់ភស្តុតាង"។

លោក គឹម លីង មន្ត្រីប្រតិបត្តិការគណបក្សសង្គ្រោះជាតិប្រចាំខេត្តព្រៃវែងបានរាយការណ៍ថា មានពាក្យបណ្តឹងសរុប២.៥៣៤ករណី រីឯមន្ត្រីគណបក្សសង្គ្រោះជាតិនៅខេត្តកណ្តាលបានប៉ាន់ប្រមាណថា មានពាក្យបណ្តឹងចំនួន១.០០០ករណី ហើយខេត្តក្រចេះបានប៉ាន់ប្រមាណថា មានពាក្យបណ្តឹងចំនួន៧០០ករណី ។

លោក សុន ឆ័យ ប្រធានក្រុមតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា ការស៊ើបអង្កេតចាប់តាំងពីថ្ងៃបោះឆ្នោតបានបញ្ជាក់ថា លោកមិនមានការសង្ស័យទេ ដែលថា គណបក្សរបស់លោកបានឈ្នះសំឡេងឆ្នោតភាគច្រើន ។

លោកបានមានប្រសាសន៍បន្តថា "ជាដំបូងយើងបានផ្តោតការយកចិត្តទុកដាក់លើការស៊ើបអង្កេតរបស់យើងនៅតាមខេត្តមួយចំនួន យើងត្រូវការសំឡេងឆ្នោតបន្តិចបន្តួចថែមទៀត ដើម្បីទទួលបានអាសនៈមួយទៀត ប៉ុន្តែបច្ចុប្បន្ននេះយើងបានដឹងថា វាមិនត្រឹមតែខេត្តទាំងនោះទេដែលមានការលួចបន្លំនោះ ។ យើងមានព័ត៌មានពីបណ្តាខេត្តធំៗដូចជាខេត្តកំពង់ចាម និងខេត្តព្រៃវែង ដែលលើកឡើងថា យើងអាចទទួលបានអាសនៈមួយទៀតក្នុងខេត្តនិមួយៗ"។

លោក សុន ឆ័យ បានមានប្រសាសន៍បន្តថា "តួលេខដំបូងនៃអាសនៈរបស់យើង គឺប្រព្រឹត្តទៅដោយស្របច្បាប់ ហើយឥឡូវនេះ យើងអាចទទួលបាន៦៥អាសនៈ ។ តួលេខនេះបានបន្តកើនឡើង ។ យើងជឿជាក់ថា គណបក្សសង្គ្រោះជាតិពិតជាឈ្នះការបោះឆ្នោតនេះ"។

| **15. Pursat** | 1. Suy Sem<br>2. Keo Ratanak<br>3. Tan Kim Vin<br>4. Em Ponna | 1. Ngim Yeng<br>2. Kuoy Kimsean<br>3. Chea Ly<br>4. Heng Por Hon | 1. San Sophal<br>2. Keo Sokna<br>3. Keo Khoeun<br>4. Hak Mak | 1. Kruth Oeun<br>2. Bo Yet<br>3. Leang Pum<br>4. Pum Sam Ath | 1. Nong Phat<br>2. Pin Lim<br>3. Kao Sambath<br>4. Meas Sao Phearith | 1. Sat Reaksa<br>2. Soth Setha<br>3. Kang Layheap<br>4. Cheal Choeun | 1. Deap Samnang<br>2. Ma Sokim<br>3. Sok Sophal<br>4. Long Mach | 1. Sok Kha<br>2. Ke Bun<br>3. Neou Lek<br>4. Chhum Pha | 4 |
| **16. Ratanakiri** | 1. Bou Lam | 1. Rin Kanha | 1. Khoeu Hun | 1. Ung Chea | 1. Kov Leav | 1. Chey Chan Davy | 1. Chhan Sean | | 1 |
| **17. Siem Reap** | 1. Tia Banh<br>2. Seang Nam<br>3. Chhim Ma<br>4. Peou Savoeun<br>5. Sam Heang<br>6. Yin Kimsean | 1. Ke Sovannaroth<br>2. Oum Sam An<br>3. Chan Seila<br>4. Im Sonith<br>5. Seiha Sovan<br>6. Mean Sophorn | 1. Sim Sun<br>2. Chea Seang Hong<br>3. Oum Somontha<br>4. Meng Hour<br>5. Pich Dara<br>6. Toch Saro | 1. Chanry Sotheara<br>2. Hoeun Sayon<br>3. Sou Chamroeun<br>4. Khong Vanna<br>5. Hoeun Sophy<br>6. Kong Roeun | 1. Khem Veasna<br>2. Tung Dany<br>3. You Khemarak<br>4. Song Youkheang<br>5. Ith Chhorb Chhorda<br>6. Mak Bunhak | 1. In Doeun Dony<br>2. Theng Ngoeun<br>3. Phin Mony<br>4. Has Hon<br>5. Tun Houen<br>6. Chhun Channary | 1. Pen Chan Sytha<br>2. So Sunthorn<br>3. Sok Tho<br>4. Ly Sreu<br>5. Chhum Mara<br>6. Tha Khorn | | 6 |
| **18. Sihanouk Ville** | 1. Chev Kimheng | 1. Sisowath Thomico | 1. Chuob Seng | 1. Heng Sareth | 1. Sun Sisamut | 1. Sok Chetra | 1. Khiev Sav | | 1 |
| **19. Steung Treng** | 1. Loy Sophat | 1. Sath Sin | 1. Som Sorphea | 1. Thin Chantho | 1. Lak Tola | 1. Lom Leng | 1. Seang Phol | | 1 |
| **20. Svay Rieng** | 1. Men Sam An<br>2. Chhun Sarim<br>3. Duong Vanna<br>4. Hul Savorn<br>5. Kim Thea | 1. Real Khemrin<br>2. Kong Saphea<br>3. Mao Sophorn<br>4. Eak Sidouch<br>5. Keo Ratana | 1. In Visaum<br>2. Yin Sokun<br>3. Mom Oam<br>4. Chhoam Chhay<br>5. Rath Sokhorn | 1. Sun Mao<br>2. Son Thol<br>3. Khim Sim<br>4. Man Saream<br>5. Srey Thim | 1. Hot Thyra<br>2. Kov Lor<br>3. Chea Sophal<br>4. Peou Sam Oun<br>5. Yim Simheng | 1. Peou Savuth<br>2. Pich Sak<br>3. Pach Sarath<br>4. Sam Vy<br>5. Peov Srey Bo | 1. Va Savan<br>2. Chan Sophal<br>3. Kong Neang<br>4. Va Bopha<br>5. Khat Chea | | 5 |
| **21. Takeo** | 1. Sok An<br>2. Nin Saphon<br>3. Mok Mareth<br>4. So Khun<br>5. Chan Sarun<br>6. Pich Sorphorn<br>7. Sok Pheng<br>8. Sok Sokan | 1. Pol Horm<br>2. Khy Vandeth<br>3. Ou Chanroth<br>4. Tep Sothy<br>5. San Seang<br>6. Ros Saravuth<br>7. Kun Lum Ang<br>8. Ouk Suy | 1. Keo Puth Rasmey<br>2. Kol Pheng<br>3. Mak Van<br>4. Prak Thavin<br>5. Pho Sothea<br>6. Kim Kosal<br>7. Nhim Saron<br>8. Bun Sophat | 1. Tuon Kimhong<br>2. Ek Chhon<br>3. Pok Hin<br>4. Hy Sokry<br>5. Cheng Sothea<br>6. Sroeun Rasmey<br>7. Nuon Neth<br>8. Kol Ra | 1. Kov Kea<br>2. Luy Phem<br>3. Mean Samros<br>4. Sim Mean<br>5. Pol Bunnang<br>6. Som Vy<br>7. Yab Roeun<br>8. Leng Cheakly | 1. Menh Kosal<br>2. Vath Tum<br>3. Kong Sarak<br>4. Chea Ching<br>5. Vath Touch<br>6. Long Samabath<br>7. Teng Taing<br>8. Soy Ith | 1. Sok Sim<br>2. Prak Rin<br>3. Ky Kha<br>4. Sem Ran<br>5. Ngeth Sokna<br>6. Yem Sibol<br>7. Sen Mengsron<br>8. Pheng Sambo | 1. Hy Sokchea<br>2. Nuon Sarom<br>3. Hy Saneoun<br>4. Chuon Thea<br>5. Thorn Piseth<br>6. Sok Buntheoun<br>7. Sok Sameth<br>8. Norng Sokha | 8 |
| **22. Kep** | 1. Cham Prasidh | 1. Sao Vibol | 1. Loeuk Khean | 1. Ren Borath | 1. Peang Channy | 1. Srey Touch | | | 1 |
| **23. Pailin** | 1. Ban Sreymom | 1. Suong Sophorn | 1. Bin Hon | 1. Pich Sophon | 1. Yoeun Yen | 1. Huon Khoeun | 1. Pok Yet | | 1 |
| **24. Oddar Meanchey** | 1. Kun Kim | 1. Sam Sambo | 1. Prum Sou | 1. Ou Khoeun | 1. Boeuy Bunneum | 1. Hang Sam Ath | 1. Thuy Sophat | | 1 |
| | | | | | | | | | **123** |

*Source: National Election Committee (This is an unofficial English version. This chart does not contain alernate candidates)*

***List of Abbreviation***

*1. CPP: Cambodian People's Party*
*2. CNRP: Cambodia National Rescue Party*
*3. FCP: FUNCINPEC Party*
*4. CNP: Cambodian National Party*
*5. LDP: League for Democracy Party*
*6. KAPP: Khmer Anti-Poverty Party*
*7. RDP: Democratic Republic Party*
*8. EDP: Economic Development Party*

## តមកពីទំព័រទី ១ វិរៈបុរសខ្មែរនៅបរទេស...

៤-ង៉ោ គីមឈៀង (Lowell-USA) ៥-គួ វ៉ាន់ចាន់(Lowell-USA) ៦-លី យក់ដា (Canada) ៧-លិម គិមយ៉ា (បារាំង) ៨-លិម ប៊ុនសីដា រ៉េត(បារាំង) ៩-ឡុង បុត្តា(បារាំង) ១០-ញូយ ចំរើន (Las vegas-USA)

លក្ខណៈដែលធ្វើឱ្យអ្នកទាំងនោះក្លាយជាវិរៈបុរសគំរូនៃប្រជាជាតិ គឺ ១-ការតស៊ូយ៉ាងព្យាយាមបំរើឧត្តមគតិបរិសុទ្ធ ហើយបានក្លាយជាលទ្ធផលល្អ ២-ធ្វើការដោយស្ម័គ្រចិត្តចំណាយកម្លាំងនិងសម្បត្តិផ្ទាល់ខ្លួន

៣-មិនប្រាថ្នា ឬធ្វើអ្វីដោយសារមានប្រយោជន៍ផ្ទាល់ខ្លួនក្នុងនោះ

៤-បរិច្ចាកដោយមានការគាំទ្រពីក្រុមគ្រួសារ

៥-ហ៊ានបូជាជីវិតប្រឈមនឹងឧបសគ្គ ឬគ្រោះថ្នាក់ចំពោះមុខ

៦-បូជាចំណេះប្រាជ្ញា ប្តេជ្ញាថែរក្សានិងការពារប្រជាពលរដ្ឋ

៧-បំរើរាស្ត្រក្នុងស្មារតីសុច្ចរិត យុត្តិធម៌ និងដោយក្តីស្រលាញ់

៨-ថែរក្សាកិត្តិយសជាអ្នកជម្រើសដ៏ខ្ពង់ខ្ពស់របស់គណបក្សសង្គ្រោះជាតិអ្នកដែលបានស្គាល់បុគ្គលទាំង១០នាក់នោះជាយូរមកហើយ សុទ្ធតែនិយាយថា អ្នកទាំងនោះ សាកសមនឹងទទួលកិត្តិយសជា "វិរៈបុរសខ្មែរនៅបរទេស" នោះណាស់ ពីព្រោះអីបានសេចក្តីសុខគ្រប់យ៉ាងនៅឯបរទេស ហើយសម្រេចចិត្តទៅចូលរួមតស៊ូយ៉ាងលំបាកវេទនាជាមួយវិរៈបុរសក្នុងស្រុកជាច្រើនឯទៀត ដើម្បីកសាងសេចក្តីសុខឱ្យជនរួមជាតិខ្លួន ។



# ផែទាំសុខភាពបេះដូង ដោយការបរិភោគបន្លែ និងផ្លែឈើ



បើចង់ឱ្យបេះដូងរឹងមាំ បានយូរអង្វែងសាកល្បងផ្អាកសាច់សត្វរួចងាកមកទទួលទានបន្លែទទួលទានផ្លែឈើឱ្យបានច្រើន ព្រោះអ្នកស្រាវជ្រាវអង់គ្លេសបានស្ទង់មតិប្រជាជន៤៤.៥០០នាក់ក្នុងប្រទេសអង់គ្លេស និងប្រទេសស្កុតឡែនដ៍បានរកឃើញថា អ្នកដែលចូលចិត្តបរិភោគបន្លែផ្លែឈើ ឬអ្នកតមសាច់មានកូឡេស្តេរ៉ុល និងមានការប្រឈមនឹងជម្ងឺបេះដូងតិចជាងអ្នកដែលទទួលទានសាច់សត្វដល់ទៅ៣២% ដោយក្នុងបន្លែ និងផ្លែឈើមានវីតាមីនច្រើន និងមិនមានចំណែកដែលទៅបង្កឱ្យស្ទះសរសៃឈាមមិនដូចសាច់សត្វដែលភាគច្រើនមានជាតិខ្លាញ់ខ្ពស់ ។

---

## តមកទំព័រទី ១៩ ខ្មែរចេញបោះឆ្នោតព្រមគ្នា.....

ដែលនៅឯកោជាងមុនត្រូវប្រឈមមុខ និងបញ្ហាអាយុជីវិតធំជាងមុនសត្រូវរបស់លោកក៏មានការប្តេជ្ញាចិត្តច្បាស់លាស់ជាងមុនហើយ និងពុំមានអាថិកំបាំងអាក្រក់ណាមួយដែលអាចឱ្យលោកប្រើប្រាស់សំរាប់ទាញយកប្រយោជន៏លោកដូចសត្រូវមុនៗនោះទេ ។ ដូច្នេះការប្រើអំណាចរដ្ឋដូចពេលមុនៗអាច និងបានទទួលផលវិបាកផ្ទុយពីពេលមុនៗពុំមាននរណាស្រោចស្រង់បានទេ។ នៅពេលមានចរន្តគំនិតចំឡែកមួយថា "សម រង្ស៊ី - កិម សុខា ប្រថុយដឹកនាំបាតុកម្មប្រជាជាតិជាកំហុសមួយ ព្រោះអាចនាំឱ្យប្រជាពលរដ្ឋទៅរកគរោះថ្នាក់តែពលរដ្ឋខ្មែរពេលនេះមានសមត្ថភាពគ្រប់គ្រាន់ដឹកនាំបាតុកម្មដោយខ្លួនឯង ទោះជាគ្មាន សម រង្ស៊ី-កិម សុខា ក៏ដោយ"គំនិតចំឡែកនោះភ្លេចថា "បាតុកម្មពលរដ្ឋជាដំណាក់ការណ៍ចាំបាច់សម្រាប់បង្ហាញឥទ្ធិពលរបស់ប្រជាជាតិក្រោយពេលបោះឆ្នោតថា លោក ហ៊ុន សែន គ្មានសល់អ្វីទៀតទេសម្រាប់បង្អាក់ការចេញដំណើររបស់ពលរដ្ឋដែលបានប្តេជ្ញាចិត្តថា ទម្លាក់លោក ហ៊ុន សែន ចោលទៅហើយនោះ"។ លោកនាយករដ្ឋមន្ត្រីផុតអាណត្តិចង់នៅក្រាញឡាំប៉ា ដូចឆ្នាំ១៩៩៣ ប្រើអំណាចព្រះមហាក្សត្រប្រើចលនាកងកម្លាំងប្រដាប់អាវុធប្រើការគម្រាមប្រើការភូតភរ... តែការសាកល្បងលើកនេះលោកដឹងថា នឹងជួបប្រទះមិនត្រឹមតែប្រជាពលរដ្ឋដែលប្រឆាំងនឹងលោកតែអ្នកដែលធ្លាប់បំរើលោកគណបក្សប្រជាជនរបស់លោក ក៏គួរឱ្យសង្ស័យថា ជាអ្នកប្រឆាំងនឹងលោកដែរ ថែមពីនេះទៅទៀត ទីស្នាក់ការសិទ្ធមនុស្សអ.ស.ប. ក៏មិនទាន់ដេញពីកម្ពុជានៅឡើយ អង្គការឃ្លាំមើលអេស៊ីយ៉ាបានតាមដានទង្វើរបស់លោកយ៉ាងជាប់ស្អិតនៅមានសហរដ្ឋអាមេរិកសហភាពអ៊ឺរ៉ុប អូស្ត្រាលី ដែលជាបក្សសម្ព័ន្ធ"អូតង់"សុទ្ធសឹងតែបានផ្តល់ការគាំទ្រឱ្យកម្លាំងដល់គណបក្សសង្គ្រោះជាតិ តាំងតែពីសម រង្ស៊ី គោចរនៅក្រៅប្រទេសនៅឡើយម្លេះ ។ ការប៉ុនប៉ងធ្វើអំពើហឹង្សាណាមួយទៅលើប្រជាពលរដ្ឋឥតអាវុធទៅលើបាតុកម្មអហឹង្សារបស់ប្រជាជន គឺជាការបំផ្លាញខ្លួនឯងនិងគណបក្សប្រជាជនកម្ពុជាយ៉ាងឆុតឆាប់ ។

នៅមានច្រកសម្រាប់រំដោះកុំឱ្យរលាយទ្រង់ទ្រាយធំបានដែរ គឺគណបក្សប្រជាជនមិនផ្ញើរវាសនាអាយុជីវិតខ្លួនក្នុងដៃ ហ៊ុន សែន ទាំងស្រុងដោយទប់ស្កាត់អំពើហឹង្សាលើប្រជាពលរដ្ឋចេញពីរដ្ឋាភិបាលទទួលយកគណកម្មាការឯករាជ្យស៊ើបអង្កេតរកសន្លឹកឆ្នោតដែលបាត់ទទួលយកលទ្ធផលសន្លឹកឆ្នោតរាស្ត្របានគ្រប់ទ្រង់ទ្រាយពេលនោះ ទោះជាលទ្ធផលចាញ់ឆ្នោតក៏ជាជ័យជំនះជាមួយប្រជាជាតិដែលសុខសប្បាយដែរ ឯការលួចសន្លឹកឆ្នោតជាអំពើបាបកម្មគ្មានដំណាងរាស្ត្រក្នុងប្រទេសប្រជាធិបតេយ្យណាទទួលយកភាពអាម៉ាសនោះបានទេ ៕






Greater Merrimack Valley Restaurant Showcase Week 2013

Presented by Greater Merrimack Valley Convention & Visitors Bureau adventures await

# Join Us...

**Sunday, August 18 to Sunday, September 1**

Restaurant Showcase Week is your chance to discover great restaurants in the region at a fantastic value.

*Special 2-Course Lunch Menu*
Prices range from $9.13 - $15.13

*Special 3-Course Dinner Menu*
Prices range from $23.13 - $33.13

**Participating Restaurants**
(as of 8/8/13)

Angelina's Italian Restaurant & Pizzeria
Athenian Corner
Bahama Breeze
Centro
Clark's at Westford Regency
Cobblestones of Lowell
50 Warren at UMass Lowell Inn and Conference Center
Glenview Pub and Grill
Grazie at Four Oaks Country Club
Heritage Farm Ice Cream & Restaurant
La Boniche
Lexx Restaurant
Major's Pub
Merchant's Row at Concord's Colonial Inn
Minuteman Grille at Holiday Inn Boxborough
Moonstones Restaurant
On the Bone at Wyndham Boston Andover
Owen and Ollie's Restaurant & Pub
Pho Dalat Vietnamese Restaurant
Red Rose Cambodian Restaurant
Ricardo's Café Trattoria
TreMonte Pizzeria
Vine Brook Tavern

**Visit www.merrimackvalley.org**

*Chateaubriand Sponsor*
Sysco — THE SUN

*Filet Mignon Sponsors*
Lexington's Colonial Times Magazine — LowellFive — merrimack valley magazine — WCAP

*Top Round Sponsor*
KhmerPost USA — Anastas Advertising Associates, Inc.

**Producing Partners:**
Greater Lowell Chamber of Commerce — Greater Merrimack Valley Convention & Visitors Bureau — Lexington Chamber of Commerce

YOUNG PROFESSIONAL LEADERSHIP PROGRAM
INVITES YOU TO:

*Come meet our future leaders.*

CMAA

GARCIA BROGAN'S
131 MIDDLESEX STREET
LOWELL, MA 01852

AUGUST 13TH, 2013
6:00-8:00PM

$25 PER PERSON
APPETIZERS, CASH BAR AND DOOR PRIZES

**Now I have someone** to drive me to the doctor.

With **UnitedHealthcare® Senior Care Options (HMO SNP),** you'll have a Personal Care Manager. Your Personal Care Manager will help you coordinate the services you may need, like rides to doctor appointments, and answer questions about staying healthy and more. It's your doctor, hospital and prescription drug coverage and independent living support in one simple plan.

- $0 copay for eyewear (up to $125 annually)
- $0 copay for dental fillings and dentures
- $0 copay for rides to doctor appointments
- $0 copay for all prescribed medications

Get more benefits in one plan at no cost to you.

Find out more today.
Call **1-888-727-8595,** TTY: **711,** or go to **UHCCommunityPlan.com.**

UnitedHealthcare®
Community Plan

UnitedHealthcare Senior Care Options (UnitedHealthcare SCO) is a voluntary program available to people who are 65 and older. UnitedHealthcare SCO is a Coordinated Care plan with a Medicare Advantage contract and a contract with the Commonwealth of Massachusetts Medicaid program. The benefit information provided herein is a brief summary, not a comprehensive description of benefits. For more information contact the plan.

MASCO 120213_173411
H2226_120213_173411 CMS Accepted

CST2965_240590

# បទសម្ភាសន៍ជាមួយ នារី រ័ត្នគន្ធា តារាសម្តែងភាពយន្តខ្មែរ និងខារ៉ាអូខេ នាទសវត្សរ៍៩០ នៅរូដអាយឡិនសហរដ្ឋអាមេរិក

**ដោយ: សុខា**









**ប្រូវីដិនស៍ រ៉ូដអាយឡិន:** ទូរទស្សនិកជន និងប្រិយមិត្តដែលនិយមគាំទ្រសិល្បការិនីខ្មែរ មានច្រមុះស្រួច ចិញ្ចើមមូលខ្វង់ រូបសម្បត្តិ-រាង រៅ មិនខ្ពស់ មិនទាប បែបស្ត្រីខ្មែរ ពោលគឺ នារី រ័ត្ន គន្ធា ប្រាកដជានៅចាំមិនភ្លេចអំពីស្នាដៃសម្តែងទាំងផ្នែកភាពយន្ត ព្រមទាំងស្នាដៃដទៃទៀត។ ថ្លែងមកកាន់សារព័ត៌មានខ្មែរផុសទាក់ទិននឹងប្រវត្តិនៃការប្រឡូកក្នុងសិល្បៈអ្នកនាង រ័ត្ន គន្ធា ផ្តើមអាជីពនេះនៅអំឡុងឆ្នាំ១៩៨៩ ដោយមិនបានព្រៀងទុកខណៈដែលអ្នកនាងទៅថតរូបកាតនៅសហគ្រាសថតរូបក្នុងរាជធានីភ្នំពេញក្បែរផ្សារថ្មី ។ ម្ចាស់ហាងស្នើឱ្យនាងថតរូបតែង និងពង្រីកធំៗដាក់ជាយីហោហាង ព្រោះជាសហគ្រាសថតរូបបើកថ្មីនាកាលនោះ។ រូបរបស់នាងក៏ត្រូវបានសាធារណជនឃើញមិនចន្លោះឡើយ។ រូបឆោមក្នុងរូបថតតាំងពីមុខហាងថតរូបនោះ បានធ្វើឱ្យនាយកដ្ឋានភាពយន្តរបស់រដ្ឋចាប់អារម្មណ៍ស្នើដល់ម្តាយនាងសុំអនុញ្ញាត្ត រ័ត្នគន្ធា ឱ្យមកសម្តែង។ គ្រានោះ ម្តាយរបស់អ្នកនាងពុំគិតថា អនុញ្ញាត្តនាងឡើយ តែគាត់ផ្តល់សិទ្ធិសម្រេចទៅលើនាយកសាលារបស់ គន្ធា ។ ខាងនាយកសាលាបានអនុញ្ញាត្ត គន្ធា ក៏ចាប់ផ្តើមសម្តែងជាតួឯកនៅអាយុ១៦ឆ្នាំជាមួយលោក ខៃ ប្រសិទ្ធ ក្នុងរឿងផ្លូវបែកជាបីឱ្យនាយកដ្ឋានភាពយន្ត។ ចំពោះឈ្មោះថា នារី រ័ត្នគន្ធា ជាឈ្មោះដែលត្រូវបានផ្តល់ដោយនាយកដ្ឋានភាពយន្តរដ្ឋផងដែរ។ គន្ធា គឺជាឈ្មោះពិតរបស់នាង។ ចំណែកនាម នារីរ័ត្នត្រូវបានផ្តល់ដោយនាយកដ្ឋានភាពយន្ត ព្រោះកាលនោះនាងផ្តើមជីវិតសិល្បៈដោយសម្តែងឱ្យភាពយន្តរដ្ឋ ហើយក្នុងន័យបង្ហាញពីរូបសម្បត្តិស្ត្រីខ្មែរដែលសម្តែងជូនរដ្ឋនាយកដ្ឋានក៏សម្រេចផ្តល់នាមឱ្យនាមថា ជា នារីរ័ត្ន គន្ធា ហើយឈ្មោះនេះក៏ត្រូវបានប្រើប្រាស់តាំងពីពេលនោះមក។ រីឈ្មោះពិតរបស់នាង គឺ សូផន សុគន្ធា យកតាមឈ្មោះឪពុកបង្កើតរបស់នាងក្រោយមកប្តូរមកឈ្មោះអ៊ុន សារីគន្ធា ដោយយកតាមឈ្មោះឪពុក ក្រោយក្រោយពេលដែល គន្ធា ព្រាត់ពីឪពុកបង្កើតដែលស្លាប់ក្នុងរដ្ឋាភិបាលខ្មែរក្រហម។ នារី រ័ត្នគន្ធា មានបងប្អូន៥នាក់ ប្រុស២នាក់ និងស្រី៣នាក់ បច្ចុប្បន្ននៅ៤នាក់ គឺប្រុស១នាក់ និងស្រី៣នាក់។ អ្នកនាង គន្ធា គឺជាកូនច្បង។

គួរបញ្ជាក់ផងដែរថា តារាសម្តែងជំនាន់ នារីរ័ត្ន គន្ធា រួមមាន សុវណ្ណ មុន្នី, អម្ពរ ទេវី, សុខស្រីមុំ, អ៊ុំសុវណ្ណនី, យុត្តរា ឆានី, ថោង ដារ៉ាឆាយ៉ា, ទេព រិនដារ៉ូ និង កែវ កល្យាណ ជាដើម។ សម្រាប់អ្នកនាងគ្រប់ឈុតឆាកសម្តែង គឺពិបាកទាំងអស់ព្រោះត្រូវបត់បែនដើរឱ្យចំតួ និងដាក់អារម្មណ៍ឱ្យស្របទៅនឹងឈុតនីមួយៗ ។ ភាគច្រើននៃតួដែលអ្នកនាងសម្តែងកន្លងមក គឺតួស្លូតសង់ទីម៉ង់ ដោយអ្នកនាងបញ្ជាក់ថា ប្រហែលជាមកពីនិស្ស័យធម្មជាតិនាំឱ្យមានដុងសម្តែងតួហ្នឹង។ ចំណង់ចំណូលចិត្តរបស់អ្នកនាង គឺការសរសេររឿង និងច្នៃសម្លៀកបំពាក់ ហើយពិនិត្យទៅសម្លៀកបំពាក់ភាគច្រើនដែលអ្នកនាងស្លៀកកាលអ្នកនាងនៅសម្តែង គឺចេញពីការច្នៃប្រឌិតរបស់អ្នកនាងផ្ទាល់ឯការដេរគឺជាងដេរជាអ្នករ៉ាប់រង។ គិតត្រលប់ថយក្រោយ នារីរ័ត្ន គន្ធា បានប្រើជីវិតក្នុងវិថីសិល្បៈអស់ជិត១៥ឆ្នាំ ហើយធ្លាប់បានទៅបរទេសរួមមានប្រទេសបារាំង អូស្ត្រាលី កាណាដា ញូហ្សេឡែន ចិន កូរ៉េ ជាដើម។ ក្រោយពី នារីរ័ត្ន គន្ធា លាឈប់ពីសិល្បៈក៏នៅស្ថានីយ៍ទូរទស្សន៍ និងផលិតកម្មនានាអញ្ជើញឱ្យសម្តែង តែអ្នកនាងបញ្ជាក់ថា មានភារកិច្ចមិនអាចដកឃ្លា។ យ៉ាងណាមិញយូរៗម្តងកាលបើមានឱកាសអ្នកនាងឆ្លៀតចូលរួមកម្មវិធីទូរទស្សន៍ ដូចជាថ្មីៗក្នុងឆ្នាំ២០១៣ អ្នកនាងចូលរួមកម្មវិធីមួយរបស់ទូរទស្សន៍ហង្សមាសដោយលើកយកបទចម្រៀងក្លិនជាប់នាសា និងសន្យាមុនគេងមកបកស្រាយកម្មវិធីនាពេលនោះហើយមានលោក ញ៉ែម សុគន្ធ ជាពិធីករ។

សព្វថ្ងៃនេះអ្នកនាង នារីរ័ត្ន គន្ធា មានកូនស្រីម្នាក់ឈ្មោះ នារី រចនា អាយុ១៥ឆ្នាំ និងកូនប្រុសម្នាក់ឈ្មោះសារីបុត្រ ឬប្រេនដិន Brandon ។ នៅសហរដ្ឋអាមេរិកអ្នកនាង នារីរ័ត្ន គន្ធា បើកហាងសម្អាង និងលក់សម្លៀកបំពាក់ប្រពៃណីមានអាវ ប៉ាក់ ហូល ផាមួង វត្ថុ ចម្លាក់ គ្រឿងអលង្កាកាឡៃ ក្រម៉ា កម្រាល ព្រោះជារបរប្រចាំត្រកូល ហើយអ្នកនាងមានជំនាញដឹងពីគុណភាពអីវ៉ាន់ក្នុងវិស័យនេះបានច្បាស់លាស់ទៀតផង ។ អតិថិជនទូទាំងសហរដ្ឋអាមេរិកអាចអញ្ជើញមកហាងរបស់អ្នកនាងផ្ទាល់ដែលមានអាស័យដ្ឋានលេខ ៧៩២ Porter Ave, Providence, RI 02907 ហើយអាចទាក់ ទងតាមលេខទូរស័ព្ទ 401 573 2705 និង 401 580 4404 ៕






តមកពីទំព័រទី ៤ ## ទស្សនៈកិច្ច សម រង្ស៊ី នៅឡូវែល...

ក៏បានណាត់ជួបពលរដ្ឋខ្មែរម្ចាស់អំណោយគាំទ្រ គណបក្សសង្គ្រោះជាតិ ដើម្បីមករាយការណ៍ និង



ថ្លែងអំណរគុណដោយនិយាយថា "បើទោះជាមានការលួចសន្លឹកឆ្នោតរាប់លានសន្លឹកទៅ ហើយក្តីគណបក្សប្រជាជននៅតែចាញ់ឆ្នោតគណបក្សសង្គ្រោះជាតិដែលបាន៦៣អាសនៈក្នុងចំណោម ១២៣អាសនៈទៅហើយ តែបើមិនលួចទៅវិញ នឹងបានអាសនៈលើសពី៨០ទៅទៀត ហេតុនេះ ហើយបានជាគណបក្សសង្គ្រោះជាតិមិនធ្វើឱ្យ ប្រជាពលរដ្ឋខកចិត្តមិនមានការចរចា គឺរកតែយុត្តិធមិតែប៉ុណ្ណោះ"។ ប្រជាពលរដ្ឋខ្មែរក្រៅប្រទេសបានសម្តែងការត្រេកអរយ៉ាងក្លៀវក្លា បានហៅលោក សម រង្ស៊ី ថា ជានាយករដ្ឋមន្ត្រីថ្មី ហើយដោយបានទទួលស្គាល់ថា ជ័យជំនះលើ គណបក្សប្រជាជនថា ជាផ្នែកមួយនៃស្នាដៃរបស់ខ្លួន ហើយបន្តរៃអង្គាសប្រាក់សម្រាប់ជួយទៅឱ្យគណបក្សសង្គ្រោះជាតិនៅកម្ពុជាតែក្នុងរយពេល២ម៉ោងប៉ុណ្ណោះ ប្រមូលបានជិត២ម៉ឺនដុល្លារ លោក សម រង្ស៊ី បន្តថា "មិនត្រឹមតែមានមនុស្សច្រើនចូលរួមទេ លុយក៏ស្រួលប្រមូលធ្វើឱ្យស្រុកខ្មែរធ្វើការបានស្រួលថែមពីនេះទៀត មិនត្រឹមតែអ្នកមានលុយគ្រប់គ្រាន់ចូលទេ សូម្បីតែអ្នកក្រីក្រក៏បេះបោចយកលុយជាញើសឈាមរបស់





ខ្លួន១ពាន់១ម៉ឺនមកជួយដែរ ខ្ញុំមានការរំភើបនឹងឃើញប្រជាពលរដ្ឋខ្មែរចង់ផ្លាស់ប្តូររបបណាស់ គេបានធ្វើឱ្យគណបក្សប្រជាជនចាញ់យ៉ាងអាម៉ាស់! នៅគ្រប់មណ្ឌលដែលមេដឹកនាំគណបក្សប្រជាជនឈរចាញ់ទាំងអស់! សូម្បីតែកូន ហ៊ុន សែន ឈរនៅកំពុងស្ពឺចាញ់តាំងពី នុត រំដួល ទៅពីឡូវែលនេះផង!"។ លោក សម រង្ស៊ី បានរំលឹកពីចរន្តថ្មី នៃក្រុមយុវជនដ៏សទ្ធិកសន្ទាប់ដែលចេញមកបោះឆ្នោតដែលលោកថា នេះពុំមែនជាវិទ្យុ ឬទូរទស្សន៍កម្ពុជាទេ គឺដោយសារតែ "ហ្វេសប៊ុគ"គេនាំគ្នាចេញមកជួយប្រទេសប្តូរអំណាចដែរ ។ តំណាងពលរដ្ឋខ្មែរ ដែលមកចូលរួមកកកុញនោះ មកពីផែនស៊ីវេនា (ក្នុងប្រមាន៥នាទី ប្រមូលប្រាក់បាន ៧០០ដុល្លារសម្រាប់ទិញទង់ជាតិទៅធ្វើបាតុកម្មនៅសេដ្ឋវិមាន) មកពីអូរេហ្គាន ពីកាណាដា ពីវ៉ាស៊ីនតោន ពីកាលីហ្វ័រនាណេត ការ៉ូឡាយណា និងពីដំបន់ច្រើនទៀតនៃស.រ.អា ៕






# ជំងឺមហារីក : យល់ដឹងពីបុព្វហេតុ និងវិធីការពារ



អត្ថបទដើមជាភាសាអង់គ្លេសនេះបានចុះផ្សាយជាច្រើនសារមកហើយនៅលើគ្រប់មធ្យោបាយផ្សព្វផ្សាយដើម្បីការយល់ដឹងនៃសាធារណជនទូទៅតែលោក គ្រួច ធីម បានអានអត្ថបទ នេះរួចហើយឃើញថា មានប្រយោជន៍ក៏បានសុំឱ្យខ្ញុំយកមកបកប្រែផ្សព្វផ្សាយបន្តទៅទៀត ដើម្បីអ្នកដែលមិនទាន់បានយល់ដឹងមានឱកាសស្រាវជ្រាវដើម្បីយល់ដឹង និងដើម្បីការពារខ្លួនព្រមទាំងការពារអ្នកដែលខ្លួនស្រឡាញ់។

**ដោយ : គឹម ភឿន**

នេះជាអត្ថបទមួយដ៏ល្អប្រសើរបំផុតម្នាក់ៗគួរតែបានអានកុំឱ្យខានអស់ពេលជាច្រើនឆ្នាំជនានុជនបានដឹងថា សម្រាប់ជំងឺមហារីកមានតែមធ្យោបាយមួយគត់សម្រាប់សាកល្បង("សាកល្បង"ជាពាក្យគន្លឹះ)រំលត់ជំងឺមហារីក ។ តែចុងក្រោយបំផុតជន ហាប គិន Johns Hopkins បានចាប់ផ្តើមប្រាប់លោកអ្នកថា "នៅមានមធ្យោបាយផ្សេងទៀត សម្រាប់ជ្រើសរើស

**រំលឹកជាថ្មីពីជំងឺមហារីកនៃលោកវេជ្ជបណ្ឌិត ស្យាស៊ី (SHASI)**

១-មនុស្សម្នាក់សុទ្ធតែមានកោសិកាមហារីកគ្រប់ៗគ្នានៅក្នុងរាងកាយរបស់ខ្លួន : កោសិកាមហារីកទាំងនេះមិនអាចមើលឃើញ ទេពេលធ្វើ "តេស"ក្នុងកំរិតស្តង់ដាតែការរកឃើញវាទាល់តែវាបង្កើនចំនួនគ្នាវាឡើងដល់កំរិតថ្នាក់រាប់កោដិឯណោះ ។ ពេលលោកវេជ្ជបណ្ឌិតប្រាប់អ្នកជំងឺក្រោយពេលព្យាបាលថា អស់មានកោសិកាមហារីកនៅក្នុងរាងកាយអ្នកទៀតហើយ នោះបានន័យថាការធ្វើតេសទាំងនោះមិនអាចរកឃើញកោសិកាទាំងនោះតែប៉ុណ្ណោះ ព្រោះហេតុអ្វី? ព្រោះចំនួនកោសិកាមហារីកនៅសល់តិចជាងកំរិតតេសស្តង់ដារ អាចមើល ឬរកឃើញតែប៉ុណ្ណោះ ។

២-កោសិកាមហារីកអាចកើតឡើងពី៦ដងទៅដល់១០ដងច្រើនជាងកោសិកាមនុស្សម្នាក់ៗអាចមានក្នុងមួយជីវិតរបស់គេ ។

៣-ពេលដែលភាពស៊ាំនឹងជំងឺរបស់បុគ្គលទាំងឡាយកាន់តែខ្លាំងក៏កោសិកាមហារីកត្រូវតែបានបំផ្លាញខ្ទេចហើយការពារកុំឱ្យវាកើនចំនួន និងមានការដុះសាច់បាន ។

៤-ពេលមនុស្សម្នាក់មានជំងឺមហារីកនោះគឺជាសញ្ញាឱ្យដឹងថា គេមានរបបអាហារមិនគ្រប់គ្រាន់ហើយ បុព្វហេតុក៏អាចបណ្តាលមកពីពូជពង្ស(ពន្ធុ)បរិស្ថាន,ចំណីអាហារនឹងកត្តានៃការរស់នៅផងដែរ ។

៥-ដើម្បីជំនះនូវការខ្វះខាតនៃចំណីអាហារគ្រប់បែបយ៉ាងនោះ ចូរផ្លាស់ប្តូររបបប្រចាំថ្ងៃ, ចូរទទួលទានឱ្យបានគ្រប់គ្រាន់នូវរបបអាហារដែលមានសុខភាពឱ្យបានពី៤ទៅ៥ដងក្នុងមួយថ្ងៃ ដោយមានអាហារបំពេញបន្ថែមដើម្បីបង្កើនភាពខ្លាំងខាងភាពស៊ាំនៃជំងឺមហារីក ។

៦-ការព្យាបាលតាមបែបគីមីសាស្រ្ត ដើម្បីបំពុលនូវកោសិកាមហារីកដែលកើនឡើងយ៉ាងរហ័សនោះក៏បានកំទេចនូវកោសិកាដែលមានសុខភាពទាំងឡាយដែលកើនឡើងយ៉ាងរហ័សនៅក្នុងខួរឆ្អឹង,ក្នុងផ្លូវរំលាយអាហារ(ក្រពះ,ពោះវៀនជាដើម) ឱ្យខ្ទេចខ្ទីអស់ទៅវិញដែរ វាធ្វើឱ្យខូចខាតដល់គ្រឿងប្រដាប់របស់រាងកាយ ដូចថ្លើម ក្រលៀន បេះដូង សួតជាដើមផងដែរ...

៧-ការព្យាបាលដោយបញ្ចេញកាំរស្មីនៃវិទ្យុសកម្មអាចពន្លត់បាននូវកោសិកាមហារីមតែក៏អាចធ្វើឱ្យរលាកមានស្លាកស្នាមនឹងធ្វើឱ្យខូចនូវកោសិកា,ជាលិកានឹងគ្រឿងប្រដាប់ដែលមានសុខភាពទាំងឡាយនៃរាងកាយអ្នកជំងឺដែរ ។

៨-ការព្យាបាលជំងឺមហារីកដោយមធ្យោបាយគីមីសាស្រ្ត ឬដោយការបញ្ចាំងរស្មីវិទ្យុសកម្មជាដំបូងអាចធ្វើឱ្យរួមតូចនូវដុំសាច់ដុះទាំងនោះមែន តែប្រសិនបើប្រើមធ្យោបាយទាំងនេះក្នុងរយៈពេលយូរវាឈប់មានប្រសិទ្ធភាពក្នុងការព្យាបាលទៀតហើយ ។

៩-ពេលដែលរាងកាយផ្ទុកពេញដោយជាតិពុលបណ្តាលមកពីមធ្យោបាយព្យាបាលទាំងពីរនោះភាពស៊ាំទប់ទល់នឹងជំងឺរបស់រាងកាយក៏ចុះខ្សោយ ឬក៏ត្រូវកំទេចអស់ទៅវិញ ។ ហេតុនេះរាងកាយក៏ត្រូវទទួលរងនូវជំងឺតម្កាត់ដែលមានមេរោគផ្សេងៗនឹងផលវិបាកទាំងឡាយមកបៀតបៀនបំផ្លិចបំផ្លាញ ។

១០-ការព្យាបាលដោយគីមីវិទ្យា នឹងដោយបញ្ចាំងកាំរស្មីវិទ្យុសកម្មបណ្តាលឱ្យកោសិកាជំងឺប្រែប្រួលហើយក្លាយជាធន់នឹងការព្យាបាលលំបាកនឹងបំផ្លាញវាបាន ។ ចំណែកឯការព្យាបាលដោយវះកាត់វិញ អាចបណ្តាលឱ្យកោសិកាមហារីកទាំងឡាយលោត ឬពង្រីកទៅទីកន្លែងដ៏ទៃផ្សេងៗទៀតបាន ។

១១-មធ្យោបាយមួយដែលមានប្រសិទ្ធភាពដើម្បីច្បាំងនឹងជំងឺមហារីក គឺបង្អត់អាហារចំពោះកោសិកាមហារីកដោយមិនផ្តល់ឱ្យវានូវអាហារដែលវាត្រូវការសម្រាប់រីកចំរើនលូតលាស់ ។

តទៅលេខក្រោយ



# វិស្វកម្មក្នុងចិត្តមនុស្ស
# The human inner engineering

**តពីលេខមុន**



និពន្ធដោយ : ម៉ៅ ច័ន្ទសំណុំ

មានកំរិតត្រឹមតែវិសាលភាពនៃម៉េម័រីដែលបានអាត់ទុកក្នុងខ្លួនប៉ុណ្ណោះពុំអាចលាតសន្ធឹងទៅក្រៅ ហើយពុំមកកំរិតទូលំទូលាយឡើយ ។ ដូច្នេះឡើយបានជាគំនិតល្អៗកើតឡើងនៅពេលមនុស្សច្រើននាក់ពិគ្រោះគ្នា ។ ការសម្រេចការងារណាមួយជាអត្តនោរច្រើនពុំទទួលបានលទ្ធផលល្អ ។ ពាក្យបូរាណខ្មែរពោលទុកមកថា : ដើរឱ្យមានបីស្រដីឱ្យមាន៤" ។

២-អ្នកវិទ្យាសាស្ត្ររកឃើញថា ៦០ទៅ៧០% នៃលំហូរគំនិតទាំងនោះមានលក្ខណៈដឹងគុណភាពកករល្អក់ ពុំភ្លឺថ្លា :

ក-លំហូរគំនិតដដែលៗ ជ្រាំងដដែលៗជាខ្សែៗ វិលខ្វាល់ដូចឆ្កែដេញខាំកន្ទុយខ្លួនឯង ។

ខ-មនុស្សតែងមានទំលាប់និន្នាការ រុករកទីមានសុវត្ថិភាព ធានាអនាគតគេសាសង់ជញ្ជាំងព្រំដែនក្នុងសកម្មភាពជីវិតប្រុងប្រយ័ត្នជានិច្ចជាហេតុបង្កឱ្យលំហូរទំនាស់នឹងខ្លួនឯង ឬអ្នកដ៏ទៃ ។

រលកផ្ទៃចិត្តល្អកកករបាត់បង់ប្រាជ្ញាពីធម្មជាតិ ។

គ-ខួរក្បាលដឹតដាមដោយសម្លេងរឿងរ៉ាវនានា ពុំចេះចប់ដូចជាពពុះផុះពីក្នុងមកជូនរឿងរ៉ាវពីអតីកាលដែលភាគច្រើនជារឿងជូរចត់ពិសពុលខ្មៅងងឹតកំហឹងគំនំជោគជាំពេញទ្រូង ភ្លើងប្រេសឆា ដុតរោលជាប់ជានិច្ច ។ ជួនកាលគេគិតទៅអនាគតបង្កើតរឿងទទេៗ ។ ធ្វើឱ្យភ័យព្រួយគិតចង់ធ្វើនេះ ឬធ្វើនោះ ខុសទំនង មួរម៉ៅស្រេ្តះ ។ ខួរក្បាលវិលវល់ពុំល្ហែល្ហើយ គេកំរទឹងដឹកល់ក្នុងពេលបច្ចុប្បន្នណាស់ ។

ឃ-ទោះបីគេរស់នៅក្នុងកាលៈទេសៈធម្មតា ទោះបីគេឋិតនៅលើគំនរទ្រព្យសម្បត្តិមហាសាល ទោះបីគេមានអំណាចឋានៈខ្ពង់ខ្ពស់កិត្តិយសឧត្តុង្គឧត្តម្គយ៉ាងណា ទោះគេមានចំណេះខ្ពស់ផុតលេខក៏ដោយគេនៅតែកើតទុក្ខគេនៅតែចិញ្ចឹមចិត្តខ្វះជានិច្ច គេនៅតែត្រូវការគេនៅតែរុករកជានិច្ចប្រញាប់ជានិច្ចពេលវេលាខ្វះជានិច្ច ។ ប្រការដែលខ្ញុំរៀបរាប់ខាងលើនេះពិតជាជាក់ស្តែងណាស់ ចូរអ្នកត្រួតពិនិត្យផងចុះ ។

ដូច្នេះជនសាមញ្ញទទួលរងកៀបសង្កត់នឹងដឹកមុខដោយម៉េម័រី ។ ទោះបីម៉េម័រី បានជួយឱ្យមនុស្សយើងមានលទ្ធភាពរស់នៅលើលោកនេះបានក៏ដោយគេនៅតែរែកពន់គុណវិបត្តិយ៉ាងច្រើនឥតគណនា ។ មនុស្សជាច្រើនលើសលប់ ត្រាំក្នុងអវិជ្ជា ពុំដឹងពុំយល់គុណវិបត្តិទាំងនោះឡើយ ហើយត្រូវទទួលរងទុក្ខសោះរិតរួតគ្រប់ពេលវេលា ។ សូមជំរាបសួរនៅមានមនុស្សមួយពពួកទៀត ដែលមានកំរិតខ្ពស់ជាងនេះ នោះគឺមនុស្សទំនើប ឬអ្នកត្រាស់ដឹង ។

### ភាគទី II លក្ខណៈវិកចំរើនរបស់មនុស្សទំនើប ឬអ្នកត្រាស់ដឹង

មនុស្សអ្នកត្រាស់ដឹងមានន័យថា ត្រាស់ដឹងអំពីសច្ចធមិ អំពីក្រិតក្រមនៅត្រង់ចំណុចណា? ដូចខ្ញុំបានជំរាបជូនកន្លងមកស្រាប់ថា មនុស្សមានសមត្ថភាពពីរយ៉ាងក្នុងខ្លួនរបស់គេ ពោលគឺគេមានសតិដឹង និងម៉េម័រី ។

តើអ្នកជ្រាបឬទេថា សត្វ និងមនុស្សខុសគ្នាត្រង់ណា? សត្វបើឃើញវាគ្រាន់តែឃើញប៉ុណ្ណោះ ។ បើឈរ វាគ្រាន់តែឈរប៉ុណ្ណោះ។ បើស៊ី វាគ្រាន់តែស៊ីប៉ុណ្ណោះ ពុំមានអ្វីលើសពីនោះឡើយ ។ ចំណែកឯមនុស្សយើងវិញ បើគេឃើញគេដឹងខ្លួនថា គេកំពុងតែមើលគេដឹងថា ភ្នែកកំពុងតែបើកសំឡឹងមើលថែមទៀត ។ បើធំក្លិនគេដឹងថា កំពុងតែធំក្លិនច្រមុះកំពុងតែទទួលក្លិនថែមទៀត ។ បើគិតគេថែមទាំងដឹងខ្លួនថា កំពុងតែគិត គេទទួលដឹងថា ខួរក្បាលកំពុងធ្វើការងាររបស់វា ។ បើខឹង ឬព្រួយគេ ថែមទាំងដឹងខ្លួនថាគេកំពុងតែខឹង ឬព្រួយគេទទួលដឹងនូវអាការៈផ្សេងៗកំពុងតែផុសឡើងក្នុងរូបកាយ និងចិត្តគេ ។ ដូច្នេះលក្ខណៈពិសេសរបស់មនុស្សយើងនោះ គឺការដឹងខ្លួនថា មានអារម្មណ៍បែបនេះ ឬបែបនោះ ការដឹងខ្លួនថា កំពុងតែ ខឹង ភ័យ ព្រួយ ធ្វើនេះធ្វើនោះ ។ ក្នុងភាសាអង់គ្លេសការមានសតិដឹងខ្លួនឯងនេះ គេបកប្រែមកថា Self Reamlisation or Self Reflection ។

ដោយផ្អែកលើភាពខុសគ្នារវាងសត្វ និងមនុស្ស ដូចពោលខាងលើមកនេះ ខ្ញុំអាចជំរាបជូនថា មនុស្សសាមញ្ញគេពុំទាន់ប្រើសមត្ថភាពសតិដឹងឱ្យបានជិតដល់នៅឡើយ ឬក៏ពុំទាន់ប្រើតែម្តងរហូតដល់ខ្លួនស្លាប់ក៏ពុំដឹងផង ។ មនុស្សសាមញ្ញប្រើតែញាណទាំង៦ : ភ្នែក ច្រមុះ អណ្តាត ស្បែក ត្រចៀក និងខួរក្បាល សំរាប់គិតពិចារណាដោះស្រាយបញ្ហានានាក្នុងដំណើរជីវិតរស់នៅប៉ុណ្ណោះ ពោលម្យ៉ាងទៀត ពួកគេបានប្រើតែម៉េម័រីប៉ុណ្ណោះ ដូចខ្ញុំរៀបរាប់ខាងលើស្រាប់ ។ ចំណែកឯអ្នកត្រាស់ដឹងគេបានប្រើញាណទាំង៦

តទៅលេខក្រោយ









## សុខភាពល្អប្រសើរក្នុងដៃលោកអ្នក

បើលោកអ្នកមានជំងឺ ឈឺហើមជើងដៃពិបាកធ្វើចលនា -ឈឺនោមច្រើន -ដេកស្រមុំកខ្លាំង -មានស្ករច្រើនក្នុងឈាម -ឡើងទម្ងន់ធាត់ -ស្បែកឡើងកន្ទួល លោកអ្នកត្រូវចាំថា មានឱសថសក្ដិសិទ្ធមានលក្ខណៈជាប្រភេទចំណី អាចជួយឱ្យសះស្បើយបានយ៉ាងឆាប់រហ័ស ។ ឱសថធម្មជាតិ ជាប្រេងចម្រាញ់ចេញពីពន្លកគ្រាប់ស្រូវមានការត្រួតពិនិត្យដោយវេជ្ជបណ្ឌិតត្រឹមត្រូវ អាចប្រើដោយមិនប្រឆាំងនឹងថ្នាំពេទ្យ ដែលប្រើប្រាស់រាល់ថ្ងៃទេ ។

លោក វិចិត្រ ភូស៊ីវុឌ ៦២ឆ្នាំ មុនប្រើ "អេមស្តា" គាត់ឈឺទឹក នោមផ្អែម ឈឺបេះដូង លើសឈាម -"អាលើជី" -ឈឺសន្លាក់ ដៃជើង ឈឺក្រពះ...។ល។

**បន្ទាប់ពីបានប្រើ "អេមស្តា"**

លេប៩គ្រាប់ក្នុង១ថ្ងៃ-បីថ្ងៃក្រោយមក អន់ឈឺសន្លាក់ដៃជើង -១ខែក្រោយអាចរត់ឡើងជណ្ដើរបាន-បីខែក្រោយទៀតសរសៃឈាម២ពែងស្ទះ-ឥឡូវនេះអាចរត់បាន១០គីឡូម៉ែត្រ-ធ្វើតេស្តឈាមមានភាពប្រក្រតីឡើងវិញ ។



**ចង់ដឹងបន្ថែមលេខទូរស័ព្ទលេខ**
-ហ្វីឡាខាងត្បូង ២១៥ ២៣៧ ៥៧០៥ សាមន់ថា
-ហ្វីឡាខាងជើង ២១៥ ៦៦៧ ៨៤៣១ វ៉ាង

## លក់ហាងប្រហ្វូហ្សិនយ៉ូហ្គឺត

ឱកាសក្លាយជាម្ចាស់ខ្ញុំហាងប្រហ្វូហ្សិនយ៉ូហ្គឺត ។ ហាងទើបតែចាប់ផ្ដើមបើកថ្មីៗនៅវីលមីងតុង (Wilnington) ។ យើងត្រូវការលក់ហាងនេះ ។ គ្មានបទពិសោធន៍ជំនួញនេះក៏អាចធ្វើបានដែរ ហើយងាយស្រួលរៀបចំថែមទៀត ។ ថ្លៃលក់ហាងថោកជាងថ្លៃដែលបានចំណាយសាងសង់ហាង ។

ថ្លៃលក់ហាង : **$200,000**

ប្រាក់ចំណូលអាចរកបាន : **$10,000** ឬច្រើនជាងនេះ ។

សូមហៅមកកាន់ : **978-967-6695**

## ANGKOR AUTO SERVICE, INC.

## ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



**BODY WORKS**

Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្សួរិនបានផង យើងផ្ដល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425



## ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្ដេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

## ក្រុមហ៊ុនទេសចរណ៍

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Cell : 267-934-9888**

## ខ្មែរជួសជុលរថយន្ត

## KHMER AUTO REPAIR

**CAR INSPECTION, DIAGNOTIC & REPAIR**

**ត្រួតពិនិត្យរថយន្តបញ្ជូរដ្ឋ**
- ឆែករកកន្លែងខូចខាត និងជួសជុល
- យើងធ្វើហ្វ្រាំង ឬប្រេក
- ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- បញ្ចេះឡានអាល់ទេណាទ័រ
- បូមចរន្តទឹកវេឌីណាទ័រ
- សេវាត្រង់បីស្យុង
- មើលតម្រងទ្រនាប់ និងពីញូង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634

# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហាង

ជោគជតាប្រចាំសប្តាហ៍

**ឆ្នាំជូត**

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

**ឆ្នាំថោះ**

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

**ឆ្នាំមមី**

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

**ឆ្នាំរកា**

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

**ឆ្នាំឆ្លូវ**

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមកហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណងហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

**ឆ្នាំរោង**

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមូលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

**ឆ្នាំមមែ**

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិត ផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញ ទៅជួញដូរនៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

**ឆ្នាំច**

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំខាល**

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែម ទើបជាការប្រសើរ ៕

**ឆ្នាំម្សាញ់**

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

**ឆ្នាំវក**

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះ សុទ្ធតែផ្តល់នូវអត្ថប្រយោជន៍គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

**ឆ្នាំកុរ**

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕


## ក្រុមហ៊ុនធានារ៉ាប់រងដែលបានបំរើសង្គម២២ឆ្នាំហើយ

## CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.

We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com

## East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products | Tummy Tuck | Breast Lift | Beast Enlargement



Nose Surgery | Eyelid Surgery | Face Lift | Dermabrasion

**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមានអាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127

**(617) 464 - 0001**

# សម្តេច ហ៊ុន សែន ធ្វើឱ្យប្រជាប្រិយភាពគណបក្សប្រជាជនធ្លាក់



គីម សុស មន្ត្រីចូលនិវត្ត ក្រសួងការបរទេស សហរដ្ឋអាមេរិក

ទស្សនៈ

**ដោយ គីម សុស**

លទ្ធផលបឋមនៃការបោះឆ្នោតជាតិនៅថ្ងៃទី២៨ខែកក្កដាឆ្នាំ២០១៣បង្ហាញឱ្យឃើញថា គណបក្សប្រជាជនទទួលបាន៦៨កៅអីនៅរដ្ឋសភា គឺធ្លាក់ចុះ២២កៅអីក្រោយពីការកើនឡើងរហូតរបស់គណបក្សនេះតាំងពីឆ្នាំ១៩៩៣ទៅដល់ទទួលបាន៩០កៅអីនៅឆ្នាំ២០០៨។

ដូច្នេះគណបក្សនេះនៅក្នុងរដ្ឋសភាអស់រយៈ២០ឆ្នាំហើយ គឺយូរដែរហើយ។ ប៉ុន្តែនេះមិនជាបញ្ហាទេ ចំពោះរឿងយូរឬឆាប់នេះ ព្រោះគណបក្សជាស្ថាប័ន។ តាមការពិតស្ថាប័នដែលរស់នៅយូរបានទាល់តែស្ថាប័ននោះជាស្ថាប័នរឹងមាំ។ ហើយម្យ៉ាងទៀតនេះគួរតែរឹងមាំឡើង ពីព្រោះរស់បាន២០ឆ្នាំហើយនោះ។ ប៉ុន្តែផ្ទុយទៅវិញ វាទៅជាខ្សោយ គឺចុះពី៩០មក៦៨។

**សំនួរ:** មូលហេតុអ្វីអ្នកណាទទួលខុសត្រូវ?

**ចំលើយ:** មានមូលហេតុច្រើន ហើយសម្តេច ហ៊ុន សែន ជាអ្នកទទួលខុសត្រូវ។ តែនៅពេលនេះខ្ញុំសុំមិនយកមូលហេតុមកវែកញែកទេ។

**សំនួរ:** មួយទៀត តើហេតុអ្វីបានជាសម្តេច ហ៊ុន សែន ជាអ្នកទទួលខុសត្រូវ? ព្រោះសម្តេចជាអ្នកដឹកនាំ។ ត្រង់ចំណុចនេះ វាមានកត្តាច្រើន






ដូចជាកត្តាគោលនយោបាយនិងកត្តាបុគ្គលជាដើម។

តាមការសង្កេតរបស់ខ្ញុំ ខ្មែរភាគច្រើនមិនសូវយកចិត្តទុកដាក់នឹងគោលនយោបាយទេ។ តាំងពីកាលដើមឡើយមកដល់បច្ចុប្បន្ននេះ រឿងបុគ្គលជារឿងសំខាន់របស់ខ្មែរ។

បើផ្អែកទៅលើលទ្ធផលបឋមនៃការបោះឆ្នោតលើកនេះ ប្រជាប្រិយភាពរបស់សម្តេច ហ៊ុន សែន ចាប់ធ្លាក់ចុះពីឆ្នាំ២០០៨មក។ មូលហេតុធំដែលធ្វើឱ្យធ្លាក់ចុះនេះមកអំពីទ្រព្យសម្បត្តិ និងពេលវេលាកាន់អំណាច បើតាមខ្ញុំយល់។

ទ្រព្យសម្បត្តិគេមើលឃើញថា សម្តេច និងគ្រួសារលោកកាន់តែមានឡើងមានឡើង។ ហើយរឿងមានឡើង មានឡើងនេះ ធ្វើឱ្យមនុស្សកាន់ច្រើនឡើងច្រើនឡើងច្រណែន ហើយមិនចូលចិត្ត។ យើងដឹងហើយថា អ្នកមានច្រើនតែមានអ្នកស្អប់ច្រើន។

វេលាកាន់អំណាច តាមខ្ញុំដឹងសម្តេច ហ៊ុន សែន កាន់អំណាច២៨ឆ្នាំហើយ។ យើងទាំងអស់គ្នាដឹងថា គ្មានធ្វើត្រូវទាំងអស់ ឬមួយរយភាគរយទេ គឺតែងតែមានខុស បើមិនច្រើនក៏បន្តិចបន្តួចដែរ។ ខ្ញុំសុំរំលឹកអាខុសបន្តិចបន្តួចនេះវាគរគ្នាទៅជាច្រើននៅពេលយូរទៅ។ សុំរំលឹកមួយទៀត មនុស្សទាំងអស់ចង់មានអំណាចចង់កាន់អំណាច។ ជាពិសេសនៅស្រុកខ្មែរអំណាចជាលុយ។ យើងឃើញអ្នកមានអំណាចនៅក្នុងរដ្ឋាភិបាលភាគច្រើនច្រើនតែជាអ្នកមាន។ នេះជាកត្តាមួយទៀតដែលបណ្តាលឱ្យមានអ្នកច្រណែន។ នៅពេលយូរចំនួនអ្នកច្រណែនមុខជាកើន។ ម្យ៉ាងទៀតមនុស្សទូរទៅមិនចង់ឃើញអ្នកណាមួយកានអំណាចយូរទេ និងមិនចង់ឃើញមុខដដែលៗដែរ។

និយាយរួមរឿងមានសម្បត្តិទ្រព្យច្រើន រឿងមានកំហុសច្រើន រឿងចង់កាន់អំណាចយូរ រឿងមិនចង់ឃើញអ្នកណាមួយកាន់អំណាចយូរ និងរឿងមិនចង់ឃើញមុខដដែលអាចបណ្តាលឱ្យមានសត្រូវ ។សម្តេចហ៊ុនសែនកាន់អំណាចយូរហើយ ដូច្នេះខ្ញុំគិតថាសម្តេចមានសត្រូវច្រើន ទាំងខាងក្នុងទាំងខាងក្រៅបក្ស។ តាមយោបល់ខ្ញុំ បើសម្តេចនៅតែកាន់អំណាចតទៅទៀត ហើយបើគណបក្សសង្គ្រោះជាតិមិនរលាយទេ គណបក្សប្រជាជននឹងបានទទួលសំឡេងភាគតិចនៅរដ្ឋសភាមិនខាននៅការបោះឆ្នោតតាមប្រព័ន្ធលទ្ធិប្រជាធិបតេយ្យនៅឆ្នាំ២០១៨។

**ទាំងអស់នេះជាទស្សនៈរបស់ខ្ញុំ។**

Mr. Sos Kem
Retired Foreign Service Officer
U.S. Department of State
soskem@yahoo.com



# Welcome to the 17th Annual Southeast Asian Water Festival

# សូមស្វាគមន៍ក្នុងពិធីបុណ្យអុំទូកឆ្នាំទី១៧



## August 17th
## 9:00-5:00PM

**Information Boots**
**ព័ត៌មាននៃឈ្មោះតូប**

- Asian American Commission
- Asian Task Force Against Domestic Violence
- Cambodian Church of the Nazarene
- HOPE Worldwide-Boston Chapter
- H & R Block
- Jeanne D'Arc Credit Union
- Jerusalem Cambodian Evangelical Church
- Life Project for Rural Cambodians
- Lowell Community Health Center
- Lowell General Hospital
- Monroe Staffing Services
- Multicultural Home Care
- Next Step Living
- Phila Nguyen— Mortgage Consultant
- Senior Whole Health
- Torpi Travel
- United Healthcare Community Plan Senior Care Options

**Merchandise Boots**
**ផលិតផលតូប**

- Allston Nails
- Amara Boutiques and Services
- Angkor Hair Design
- Bopha Bridal Shop
- CamboFresh Clothing
- Carradine Kem
- CNC
- Creative Design
- Cultural Shock
- Good Day Video
- Herbal Life Distributor
- Kampuchea Video Store
- Lo Chung
- Mike Cipolla & Olathai Viengkham
- Paew Gift Shop
- Pink Princess
- Quality Resources
- SV Oriental Market
- Sath Thoeut
- Toy Hansana
- Vathana
- Wings of Hope Alliance for Cambodia

**អាហារតាមបណ្តាយផ្លូវ**
**Food Vendors**

- Bai Boon
- Bubble Btea House
- Dixie-Bella-Thai
- Esan Sausages
- Fresh Sugar Cane Drink
- International Provision Inc. Location 1
- International Provision Inc. Location 2
- Jasmine Thai Restaurant
- Panny Sem
- Phommalinh
- Siri Grill
- Thai Angel Restaurant
- Thai House Restaurant
- Thai Market
- Toy Hansana



**Board of Directors**
**គណកម្មការ**

Van Pech, President
Molyka Tieng, Vice President
Douang Phommasinh, Clerk
Brian Sok, Treasurer
PK Phoumyvong
Eric Sack
Sayon Soeun
Ghla Srithong
Dahvy Tran

**Volunteers**
**អ្នកស្ម័គ្រចិត្ត**

Ghla Srithong
Dahnie Tran
Cheryl Kim
Chris Samaras

**ក្រុមប្រណាំងទូក**
**BOAT TEAM**

Angkorian Warriors (CASA)
ក្រុមទ័ពអង្គរ

Family Unity Boat Team (H&R Block)
ក្រុមគ្រួសារសាមគ្គី

Living Root - Chips
ក្រុមគ្រាប់ពូជអមតៈ-ដំឡូង

Living Root - Fish
ក្រុមគ្រាប់ពូជអមតៈ-មច្ឆា

Lucky Ducky (EMC Canoe Adventure Club)
ក្រុមទាសំណាង

Payanak
ក្រុមបាយ៉ាណាក់




**កម្មវិធីប្រកួត និងសម្តែង សូមមើលទំព័រទី០៧**

See page 7 for Schedule of the event